# បេឡាជាតិរបបសន្តិសុខសង្គម
# National Social Security Fund

# របាយការណ៍
## ស្តីពី
## សមិទ្ធផលរយៈពេល ១០ឆ្នាំ ( ២០០៨ - ២០១៧ )
## និងទិសដៅការងារឆ្នាំ ២០១៨



ការអនុវត្តរបបសន្តិសុខសង្គម

រួមមាន ៖ ផ្នែកហានិភ័យការងារ   ផ្នែកថែទាំសុខភាព   ផ្នែកប្រាក់សោធន







ធានាសន្តិសុខប្រាក់ចំណូល   រួមចំណែកកាត់បន្ថយភាពក្រីក្រ   លើកកម្ពស់ស្ថិរភាពសង្គម

# បេឡាជាតិរបបសន្តិសុខសង្គម
## National Social Security Fund

# របាយការណ៍
## ស្តីពី
## សមិទ្ធផលរយៈពេល ១០ឆ្នាំ ( ២០០៨ - ២០១៧ )
## និងទិសដៅការងារឆ្នាំ ២០១៨

ការអនុវត្តរបបសន្តិសុខសង្គម

រួមមាន ៖

- ផ្នែកហានិភ័យការងារ
- ផ្នែកថែទាំសុខភាព
- ផ្នែកប្រាក់សោធន

ធានាសន្តិសុខប្រាក់ចំណូល    រួមចំណែកកាត់បន្ថយភាពក្រីក្រ    លើកកម្ពស់ស្ថិរភាពសង្គម

# មាតិកា

- **ចក្ខុវិស័យ បេសកកម្ម និងគោលដៅ**......I
- **អក្ខរាវិរុទ្ធលេខរបស់ ប.ស.ស**......II
**I. សេចក្តីផ្តើម**......១
**II. សមិទ្ធផលរយៈពេល ១០ឆ្នាំ (២០០៨-២០១៧)**......២
**ក. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ**......២
**១. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ**......២
១.១. ការងារបញ្ជិកា និងភាគទាន......២
១.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម......៥
១.៣. ការផ្តល់សេវាតាវកាលិក......៦
១.៤. ការងារស្តារនីតិសម្បទា......១០
**២. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**......១១
២.១. ការងារបញ្ជិកា និងភាគទាន......១១
២.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម......១២
២.៣. ការផ្តល់សេវាតាវកាលិក......១៣
**៣. ជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**......១៣
**ខ. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**......១៤
**គ. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនិងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន**......១៤
១. ការងារបញ្ជិកា......១៤
២. ការផ្តល់តាវកាលិក......១៥
៣.ការបើកប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន......១៥
**ឃ. ការងារគាំទ្រការអនុវត្ត**......១៥
**១. ការងាររៀបចំគោលនយោបាយ និងលិខិតគតិយុត្ត**......១៥
**២. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស**......១៦
២.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ......១៦
២.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស......១៧
២.៣. ការងារព័ត៌មានវិទ្យា......២១
២.៤. ការងារសវនកម្មផ្ទៃក្នុង......២៣
២.៥. គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស......២៣
**៣. ការងារប្រជុំផ្សព្វផ្សាយ និងបង្ការ**......២៤
៣.១. ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយរបបសន្តិសុខសង្គម......២៥

៣.២. ក្រុមការងារប.ស.សសហការជាមួយក្រុមការងារផ្សព្វផ្សាយពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ........ ២៥
៣.៣. ការងារប្រជុំផ្សព្វផ្សាយបង្ការហានិភ័យការងារ........ ២៥
៣.៣.១. ក្រុមការងារ ទ.ស.ប.ក........ ២៥
៣.៣.២. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត........ ២៧
III. **បញ្ហាប្រឈម**........ **២៨**
IV. **ការដោះស្រាយ និងទិសដៅអនុវត្តបន្ត**........ **៣០**
V. **សេចក្តីសន្និដ្ឋាន**........ **៣៣**
- ការិយាល័យសាខាបេឡាជាតិរបបសន្តិសុខសង្គមតាមរាជធានី-ខេត្ត........ ៣៤
- ព្រះរាជក្រឹត្យស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន........ ៣៧
- អនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន........ ៤៤
- ប្រកាសស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន........ ៦៥
- **ឧបសម្ព័ន្ធ**........
- បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត........ ៧០
- បច្ចុប្បន្នភាពសហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើងថ្នាក់កណ្តាល/ថ្នាក់ខេត្ត........ ៧១

# ចក្ខុវិស័យ និងបេសកកម្ម

## ចក្ខុវិស័យ

ធានាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## បេសកកម្ម

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។

## គោលដៅ

១. ពង្រីក និងពង្រឹងការអនុវត្តផ្នែកហានិភ័យការងារ (គ្រោះថ្នាក់នៅកន្លែងធ្វើការ, គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ)
២. ដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាព (សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ, សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះនិងសេវាបញ្ជូនសព, ប្រាក់បំណាច់ប្រចាំថ្ងៃ និងសេវាបង្ការសុខភាព)
៣. ដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន (ជរាភាព, ទុព្វលភាព, មរណភាព)

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)



# របាយការណ៍
## សមិទ្ធផលរយៈពេល ១០ឆ្នាំ (២០០៨-២០១៧) និងទិសដៅការងារឆ្នាំ២០១៨
## របស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

**I. សេចក្តីផ្តើម**

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ, ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ត្រូវបានអនុវត្តអនុលោមតាមច្បាប់ស្តីពីការងារ និងអនុក្រឹត្យស្តីពីការបង្កើត ប.ស.ស ដោយស្របតាមយុទ្ធសាស្ត្រចតុកោណ, យុទ្ធសាស្ត្រអភិវឌ្ឍជាតិ, យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

អនុលោមតាមច្បាប់ និងផែនការយុទ្ធសាស្ត្រខាងលើ ប.ស.ស បានដាក់ផែនការអនុវត្តជំហានទី១ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ព្រមទាំងទទួលបានការគាំទ្រទាំងនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ។

ក្នុងរយៈពេល ១០ឆ្នាំ គិតចាប់ពីឆ្នាំ២០០៨ ដល់ដំណាច់ឆ្នាំ២០១៧ ការដាក់ឱ្យដំណើរការជំហានទី១ ផ្នែកហានិភ័យការងារ ដែលទទួលបានជោគជ័យនេះ វាជាចលករដ៏សំខាន់មួយទៀតក្នុងការជួយជម្រុញឱ្យ ប.ស.ស អនុវត្តជំហានទី២ ផ្នែកថែទាំសុខភាព ដល់កម្មករនិយោជិត។ ទន្ទឹមនឹងភាពជោគជ័យ ប.ស.ស ក៏បានរកឃើញនូវបញ្ហាមួយចំនួនផងដែរទាំងចំណុចខ្លាំង និងចំណុចខ្សោយ ដែលជាបទពិសោធន៍ដ៏មានសារៈសំខាន់មួយទៀតសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តជំហានទី១ និងការអនុវត្តជំហានទី២ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជូនដល់កម្មករនិយោជិត ក្នុងទិសដៅលើកកម្ពស់សុខភាពកម្មករនិយោជិត និងជំហានទី៣ ផ្នែកប្រាក់សោធន ដែលនឹងដាក់ឱ្យអនុវត្តក្នុងពេលដ៏ខ្លីខាងមុខនេះ។

ដើម្បីលើកកម្ពស់សុខុមាលភាពសង្គមឱ្យបានកាន់តែប្រសើរ និងធានាសង្គតិភាពក្នុងការគាំពារផ្នែកហានិ-ភ័យការងារ និងផ្នែកថែទាំសុខភាពរវាងកម្មករនិយោជិតក្នុងវិស័យឯកជន និងមន្ត្រីរាជការក្នុងវិស័យសាធារណៈ និងដោយមានការផ្តល់ទំនុកចិត្ត សេចក្តីជឿជាក់ទាំងស្រុងចំពោះសមិទ្ធផលកន្លងមករបស់ ប.ស.ស រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចថ្មីក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនតាមរយៈព្រះរាជក្រឹត្យ នស/រកត/០៣១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីបង្កើតឱ្យមានការគាំពារផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ឱ្យមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករនិយោជិតដែលកំពុងអនុវត្តជាធរមាន។

ជាមួយគ្នានេះ ដោយមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលគ្រប់កម្មករនិយោជិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធទាំងអស់មានសិទ្ធិទទួលបានការគាំពារសង្គម តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស ជាសេនាធិការបានរៀបចំប្រកាសអន្តរក្រសួង រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល លេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា

ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។

ប.ស.ស សង្ឃឹមយ៉ាងមុតមាំថា តាមរយៈសមិទ្ធផលការងារសម្រេចបានរយៈពេល ១០ឆ្នាំកន្លងមកនេះ វានឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់វាស់វែងតាមដាន និងវាយតម្លៃលើការអនុវត្តវិស័យសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌ សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ហើយវាជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញពីចំណុចវិជ្ជមាន និងអវិជ្ជមាន ព្រមទាំងបញ្ហាប្រឈមនានា ដើម្បីធ្វើការកែតម្រូវ និងធ្វើការដោះស្រាយសម្រាប់រៀបចំទិសដៅអនុវត្តបន្តឱ្យបានកាន់តែល្អប្រសើរថែមទៀត។

## II. សមិទ្ធផលរយៈពេល ១០ឆ្នាំ (២០០៨-២០១៧)

### ក. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

### ១. ពង្រីក និងពង្រឹងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

#### ១.១. ការងារបញ្ជិកា និងភាគទាន

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបង់ភាគទានហានិភ័យការងារមកក្នុង ប.ស.ស។ ក្នុងដំណាក់កាលចាប់ដំណើរការដំបូង នៃ ប.ស.ស ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួន ០៨នាក់ឡើង។ អត្រាភាគទានផ្នែកហានិភ័យការងារជា អត្រាឯកភាពដែលត្រូវបានកំណត់ស្មើនឹង ០,៨ភាគរយ នៃប្រាក់ឈ្នួលមធ្យម ក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

##### ១.១.១. ការងារចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

ចាប់តាំងពីដំណើរការដំបូងនាខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមកដល់ឆ្នាំ២០១៧ នេះ ប.ស.ស បានពង្រីកវិសាលភាពផ្នែកហានិភ័យការងារ គ្របដណ្តប់នៅទូទាំងប្រទេស និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សរុបចំនួន ១០ ៨៤៩សហគ្រាស មានកម្មករនិយោជិត សរុបចំនួន ១ ៤៣៥ ៣១៦នាក់ ស្រីចំនួន ៨៦៨ ១៨៦នាក់ ត្រូវជា ៦០,៤៨ភាគរយ។

## ក្រាហ្វិកទី១. ស្ថានភាពសហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាតាមរាជធានី-ខេត្ត ឆ្នាំ២០០៨-ឆ្នាំ២០១៧




### តារាងទី ១ សហគ្រាសចុះបញ្ជិកា និងសមាជិកសរុប

| បរិយាយ | សហគ្រាសចុះបញ្ជិកា និងសមាជិកសរុប | | | សហគ្រាសចុះបញ្ជិកា និងសមាជិកថ្មី | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| **ឆ្នាំ2008- ឆ្នាំ2017** | **10,849** | **1,435,316** | **868,186** | 2,118 | 299,045 | 70,159 | 909 | 44,405 | 20,561 | 1,209 | 254,640 | 49,598 |
| ឆ្នាំ2008- ឆ្នាំ2016 | 8,731 | 1,136,271 | 798,027 | 935 | 59,192 | 36,014 | 426 | 24,969 | 14,425 | 509 | 34,223 | 21,589 |
| ឆ្នាំ2008- ឆ្នាំ2015 | 7,796 | 1,077,079 | 762,013 | 755 | 55,491 | 36,686 | 388 | 31,426 | 20,640 | 367 | 24,065 | 16,046 |
| ឆ្នាំ2008- ឆ្នាំ2014 | 7,041 | 1,021,588 | 725,327 | 934 | 174,413 | 125,605 | 576 | 88,195 | 55,470 | 358 | 86,218 | 70,135 |
| ឆ្នាំ2008- ឆ្នាំ2013 | 6,107 | 847,175 | 599,722 | 1,524 | 79,041 | 56,119 | 840 | 34,166 | 19,457 | 684 | 44,875 | 36,662 |
| ឆ្នាំ2008- ឆ្នាំ2012 | 4,583 | 768,134 | 543,603 | 1,478 | 93,917 | 66,681 | 595 | 30,811 | 20,136 | 883 | 63,106 | 46,545 |
| ឆ្នាំ2008- ឆ្នាំ2011 | 3,105 | 674,217 | 476,922 | 1,195 | 79,531 | 56,864 | 844 | 41,515 | 29,574 | 351 | 38,016 | 27,290 |
| ឆ្នាំ2008- ឆ្នាំ2010 | 1,910 | 594,686 | 420,058 | 927 | 143,454 | 101,852 | 550 | 71,827 | 46,172 | 377 | 71,627 | 55,680 |
| ឆ្នាំ2008- ឆ្នាំ2009 | 983 | 451,232 | 318,206 | 656 | 387,046 | 279,695 | 567 | 259,411 | 190,370 | 89 | 127,635 | 89,325 |
| ឆ្នាំ2008 | 327 | 64,186 | 38,511 | 327 | 64,186 | 38,511 | 327 | 64186 | 38511 | 0 | 0 | 0 |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម (២០០៨ ដល់ ២០១៧)

### តារាងទី ២. បច្ចុប្បន្នភាព សហគ្រាស គ្រឹះ ស្ថាន និងកម្មករនិយោជិត

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2017 | 8,507 | 1,182,849 | 787,547 | 4,435 | 627,637 | 389,029 | 4,072 | 555,212 | 398,518 |
| ឆ្នាំ2016 | 6,884 | 1,108,759 | 752,459 | 3,832 | 611,064 | 396,987 | 3,052 | 497,695 | 355,472 |
| បម្រែបម្រួល (± %) | 23.58% | 6.68% | 4.66% | 15.74% | 2.71% | -2.00% | 33.42% | 11.56% | 12.11% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2017 (ទិន្នន័យលំអិតសូមមើលក្នុងតារាងឧបសម្ព័ន្ធទី 1)

### តារាងទី ៣. បច្ចុប្បន្នភាព សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើង ថ្នាក់កណ្តាល -ថ្នាក់ខេត្ត

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2017 | 1,021 | 696,554 | 576,772 | 626 | 341,023 | 279,441 | 395 | 355,531 | 297,331 |
| ឆ្នាំ2016 | 1,006 | 687,686 | 566,645 | 646 | 362,001 | 298,371 | 360 | 325,685 | 268,274 |
| បម្រែបម្រួល (± %) | 1.49% | 1.29% | 1.79% | -3.10% | -5.80% | -6.34% | 9.72% | 9.16% | 10.83% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2017 (ទិន្នន័យលំអិតសូមមើលក្នុងតារាងឧបសម្ព័ន្ធទី 2)

### ១.១.២. ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា

ចាប់ពីឆ្នាំ២០០៨ ដល់ដំណាច់ឆ្នាំ២០១៧ នេះ ប.ស.ស បានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ចំនួន ១០ ៨៤៩ ក្នុងនោះកាត់ដេរ ចំនួន ៦ ៤៩២, វិស័យសណ្ឋាគារមាន ចំនួន ៣៩៩, បំរើសេវាកម្មផ្សេងៗ ចំនួន ២១២, ភោជនីយដ្ឋាន ចំនួន ២១៩, , អង្គការ ចំនួន១៦២, និងសហគ្រាសផ្សេងៗទៀត ចំនួន ៣ ៣៦៥។

### ១.១.៣. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ

*តារាងទី ៤. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល -ថ្នាក់ខេត្ត*

| សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្តាល -ថ្នាក់ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | បិទទ្វារ | | | ផ្អាកដំណើរការ | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| **ឆ្នាំ2008-ឆ្នាំ2017** | **2,342** | **252,467** | **80,639** | 2,241 | 244,178 | 77,090 | 101 | 8,289 | 3,549 |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2008-ឆ្នាំ2017

ជាការគួរឱ្យកត់សំគាល់ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន ដែលបានឈប់ដំណើរការខាងលើរហូតមកដល់ពេលនេះ មានសហគ្រាស គ្រឹះស្ថាន មួយចំនួនបានបើកដំណើរការឡើងវិញហើយ ដែលក្នុងនោះមួយចំនួនបានប្តូរឈ្មោះ មួយចំនួនទៀតបានប្តូរម្ចាស់ ដែលភាគច្រើនជាសិប្បកម្ម, ឡតដ្ឋ, ភោជនីយដ្ឋាន ,.....ដែលមានទីតាំងនៅឆ្ងាយ។

### ១.១.៤. ក្រាហ្វិចការខារចុះបញ្ជិកា ឆ្នាំ២០០៨-ឆ្នាំ២០១៧

*ក្រាហ្វិកទី២. សហគ្រាសចុះបញ្ជិកា ឆ្នាំ២០០៨- ឆ្នាំ២០១៧*



*ក្រាហ្វិកទី៣. សមាជិកចុះបញ្ជិកា ឆ្នាំ២០០៨- ឆ្នាំ២០១៧*




## ១.១.៥. ការងារភាគទាន

ក្នុងចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ដែលបានចុះបញ្ជិកា បេឡាជាតិរបបសន្តិសុខសង្គម បានដាក់ឱ្យជាប់ភាគទាន ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧ មានដូចខាងក្រោម៖

**តារាងទី ៥ សហគ្រាស គ្រឹះស្ថាន សរុប បានបង់ភាគទាន**

| បរិយាយ | សហគ្រាសជាប់ភាគទាន (មធ្យមភាគ) | សហគ្រាសបានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | | ភាគទាន (ប៊ីលានរៀល) | ភាគរយសហគ្រាសបានបង់ភាគទាន |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | |
| ឆ្នាំ2017 | 6,866 | 6,104 | 1,156,675 | 793,085 | 91.88 | 89% |
| ឆ្នាំ2016 | 6,618 | 5,416 | 1,042,143 | 723,312 | 82.70 | 82% |
| ឆ្នាំ2015 | 6,140 | 5,622 | 1,038,151 | 726,705 | 74.33 | 92% |
| ឆ្នាំ2014 | 5,758 | 4,966 | 908,535 | 635,975 | 57.29 | 86% |
| ឆ្នាំ2013 | 4,749 | 4,577 | 824,011 | 576,808 | 43.14 | 96% |
| ឆ្នាំ2012 | 3,886 | 3,459 | 694,199 | 478,998 | 30.48 | 89% |
| ឆ្នាំ2011 | 2,450 | 2,182 | 573,023 | 395,386 | 24.31 | 89% |
| ឆ្នាំ2010 | 1,608 | 1,444 | 481,010 | 331,897 | 14.37 | 90% |
| ឆ្នាំ2009 | 605 | 553 | 317,224 | 222,057 | 8.02 | 91% |
| ឆ្នាំ2008 | 322 | 301 | 256,316 | 176,858 | 1.47 | 93% |
| សរុបភាគទាន | | | | | 427.98 | |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2008 ដល់ ឆ្នាំ2017

## ១.២. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម មានមុខងារក្នុងការធានាឱ្យមានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗជាធរមាន។ ផ្នែកនេះផ្តោតជាសំខាន់លើការងារមួយចំនួនមានជាអាទិ៍ ការចុះពន្យល់ណែនាំម្ចាស់សហគ្រាស គ្រឹះស្ថានស្តីពីការអនុវត្តគោលនយោបាយអនុវត្តរបបសន្តិសុខសង្គម ដើម្បីឱ្យមានការចុះបញ្ជិកា និងបង់ភាគទាននៅ ប.ស.ស, ការចុះអង្កេតគ្រោះថ្នាក់ការងារ, ការអង្កេតអំពីស្ថានភាពរបស់អ្នករស់នៅក្នុងបន្ទុករបស់ជនរងគ្រោះ,

ការពង្រឹងការអនុវត្តច្បាប់តាមរយៈការធ្វើអធិការកិច្ច, ការដាក់កំហិត, ការពិន័យ និងការដាក់បណ្ដឹងទៅតុលាការក្នុងករណីសហគ្រាស គ្រឹះស្ថានមិនព្រមអនុវត្តតាមច្បាប់។

លទ្ធផលចុះអធិការកិច្ច ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧ សរុបចំនួន ១៦ ៥០៧លើក ស្មើនឹង ៦៣ ៥៧៣ (ដងសហគ្រាស) ក្នុងនោះបានដាក់ពិន័យមិនព្រមចុះបញ្ជិកា ចំនួន ៩០១សហគ្រាស និងមិនបង់ភាគទានចំនួន ២១៧សហគ្រាស។

### ១.២.១. ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម

| តារាងទី៦ ការងារអធិការកិច្ច | | | | |
|---|---|---|---|---|
| បរិយាយ | ការចុះអធិការកិច្ច ចុះបញ្ជិកា | ការចុះអធិការកិច្ច ការងារតែមួយ | ការចុះអធិការកិច្ច ទារភាគទាន | ការងារផ្សេងៗ ផ្នែកអធិការកិច្ច |
| | ដងសហគ្រាស | ដងសហគ្រាស | ដងសហគ្រាស | ដងសហគ្រាស |
| ឆ្នាំ2017 | 2,193 | 284 | 490 | 14,766 |
| ឆ្នាំ2016 | 2,648 | 1,381 | 695 | 1,588 |
| ឆ្នាំ2015 | 3,384 | 1,697 | 311 | 1,016 |
| ឆ្នាំ2014 | 2,501 | 1,844 | 680 | 1,306 |
| ឆ្នាំ2013 | 9,087 | - | 292 | 1,350 |
| ឆ្នាំ2012 | 3,732 | - | 1,434 | 336 |
| ឆ្នាំ2011 | 3,556 | - | 191 | 1,762 |
| ឆ្នាំ2010 | 2,265 | - | 67 | 623 |
| ឆ្នាំ2009 | 705 | - | 43 | 1,346 |
| ឆ្នាំ2008 | - | - | - | - |
| សរុប | 30,071 | 5,206 | 4,203 | 24,093 |

### ១.២.២. ការងារនីតិកម្ម

បានចុះធ្វើការផាកពិន័យការចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន ចំនួន ៦៣៥សហគ្រាស ផាកពិន័យ មិនបង់ភាគទាន សហគ្រាស គ្រឹះស្ថាន ចំនួន ២១៧ សហគ្រាស និងបន្តតាមដាននីតិវិធីតាមផ្លូវច្បាប់ចំពោះ សហគ្រាស គ្រឹះស្ថាន ចំនួន ៤៩ ដែលបានប្ដឹងទៅសាលាដំបូងរាជធានីភ្នំពេញ ដែលមានកំហុសទាក់ទងនឹងការរាយការណ៍ចំនួនកម្មករនិយោជិតមក ប.ស.ស មិនត្រឹមត្រូវ, ការប្រកាសប្រាក់ឈ្នួល មិនត្រឹមត្រូវ, ការមិនបង់ភាគទាន, ការជំទាស់នឹងការអនុវត្តមុខងារអធិការ ប.ស.ស ព្រមទាំងពិន័យផ្សេងៗទៀតជាដើម។

## ១.៣. ការផ្ដល់សេវាតាមកាលិក

ថ្វីត្បិតចំនួនគ្រោះថ្នាក់ការងារបានបន្តកើតមានជាបន្តបន្ទាប់ក្ដីក៏ដោយ ប.ស.ស បានរៀបចំអភិវឌ្ឍន៍បែបបទការងារ និងបានពង្រីកយន្តការនៃការផ្ដល់តាវកាលិកឱ្យកាន់តែមានភាពងាយស្រួលទូលំទូលាយបន្ថែមទៀត ដើម្បីឱ្យកម្មករនិយោជិត ដែលទទួលរងនូវគ្រោះថ្នាក់ការងារទទួលបានសេវាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ តាមរយៈនេះ ប.ស.ស បានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យទាមទារ

តាវកាលិកហានិភ័យការងារ ដែលប្រព័ន្ធនេះអាចគ្រប់គ្រងបាននូវរបាយការណ៍ហានិភ័យការងារ ការអង្កេត និងការគណនាតាវកាលិក ដែលវាបានពន្លឿនក្នុងការផ្តល់តាវកាលិក និងមានភាពត្រឹមត្រូវ។ ប.ស.ស ក៏បានពង្រីកការចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសាធារណៈ និងឯកជនបានចំនួន ១២២មូលដ្ឋាន និងបានដាក់ភ្នាក់ងារឱ្យប្រចាំការនៅតាមមន្ទីរពេទ្យបានមួយចំនួន សម្រាប់ជួយសម្របសម្រួលដល់ជនរងគ្រោះ ដែលជាសមាជិករបស់ ប.ស.ស ឱ្យទទួលបានការសម្រាកព្យាបាល និងងាយស្រួលទទួលបានសេវានៅកន្លែងដែលជិត។ មួយវិញទៀតក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប.ស.ស បានបញ្ជូនមន្ត្រីទៅដល់កន្លែងគ្រោះថ្នាក់ផ្ទាល់ ដើម្បីជួយសម្របសម្រួល និងធ្វើអន្តរាគមន៍បានទាន់ពេលវេលា។

### ១.៣.១. របាយការណ៍ហានិភ័យការងារ

ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧ នេះ ប.ស.ស បានទទួលរបាយការណ៍ហានិភ័យការងារពីបណ្តាសហគ្រាស គ្រឹះស្ថាន តាមបណ្តារាជធានី-ខេត្ត នៅទូទាំងប្រទេស។

**តារាងទី ០៧ ស្ថានភាពហានិភ័យការងារ**

| បរិយាយ | ស្ថានភាពរបាយការណ៍ហានិភ័យការងារ | | | | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទទួលរបាយការណ៍ហានិភ័យការងារ (នាក់) | | សមាជិកសរុប | ផលធៀប | សរុប | | ស្រាល | | ធ្ងន់ | | ស្លាប់ | |
| | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2017 | 47,496 | 36,024 | 1,435,316 | 3.31% | 45,882 | 34,773 | 42,716 | 33,029 | 2,944 | 1,671 | 222 | 73 |
| ឆ្នាំ2016 | 36,734 | 27,338 | 1,136,271 | 3.23% | 34,513 | 25,683 | 31,899 | 24,162 | 2,446 | 1,461 | 168 | 60 |
| ឆ្នាំ2015 | 30,919 | 22,764 | 1,077,079 | 2.87% | 30,281 | 22,273 | 27,804 | 20,802 | 2,296 | 1,404 | 181 | 67 |
| ឆ្នាំ2014 | 19,425 | 14,410 | 1,021,588 | 1.90% | 18,699 | 13,820 | 17,216 | 13,003 | 1,387 | 790 | 96 | 27 |
| ឆ្នាំ2013 | 16,849 | 12,034 | 847,175 | 1.99% | 16,775 | 12,030 | 15,452 | 11,310 | 1,227 | 690 | 96 | 30 |
| ឆ្នាំ2012 | 14,761 | 11,023 | 768,134 | 1.92% | 14,233 | 10,709 | 13,603 | 10,354 | 571 | 333 | 59 | 22 |
| ឆ្នាំ2011 | 13,167 | 10,276 | 674,217 | 1.95% | 12,571 | 9,734 | 12,084 | 9,492 | 440 | 227 | 47 | 15 |
| ឆ្នាំ2010 | 8,498 | 6,644 | 594,686 | 1.43% | 7,611 | 5,878 | 7,214 | 5,652 | 358 | 206 | 39 | 20 |
| ឆ្នាំ2009 | 3,792 | 3,072 | 451,232 | 0.84% | 3,547 | 2,872 | 3,355 | 2,754 | 176 | 108 | 16 | 10 |
| ឆ្នាំ2008 | N/A | N/A | 64,186 | N/A | 107 | 78 | 91 | 65 | 15 | 12 | 1 | 1 |
| **សរុប 2008-2017** | **191,641** | **143,585** | | | **184,219** | **137,850** | **171,434** | **130,623** | **11,860** | **6,902** | **925** | **325** |

| តារាងទី០៨ លទ្ធផលអង្កេតហានិភ័យការងារ (ប្រភេទថ្នាក់គ្រោះថ្នាក់) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បរិយាយ | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | |
| | សរុប | | គ្រោះថ្នាក់កន្លែងធ្វើការ | | គ្រោះថ្នាក់ពេលធ្វើដំណើរ | | ជំងឺវិជ្ជាជីវៈ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2017 | 45,882 | 34,773 | 34,567 | 27,736 | 11,300 | 7,024 | 15 | 13 |
| ឆ្នាំ2016 | 34,513 | 25,683 | 24,902 | 19,477 | 9,608 | 6,204 | 3 | 2 |
| ឆ្នាំ2015 | 30,281 | 22,273 | 22,487 | 17,280 | 7,791 | 4,991 | 3 | 2 |
| ឆ្នាំ2014 | 18,699 | 13,820 | 14,022 | 10,896 | 4,674 | 2,923 | 3 | 1 |
| ឆ្នាំ2013 | 16,775 | 12,030 | 12,060 | 9,007 | 4,703 | 3,015 | 12 | 8 |
| ឆ្នាំ2012 | 14,233 | 10,709 | 10,573 | 8,342 | 3,642 | 2,357 | 18 | 10 |
| ឆ្នាំ2011 | 12,571 | 9,734 | 9,006 | 7,386 | 3,565 | 2,348 | - | - |
| ឆ្នាំ2010 | 7,611 | 5,878 | 5,109 | 3,946 | 2,502 | 1,932 | - | - |
| ឆ្នាំ2009 | 3,547 | 2,872 | 2,523 | 2,043 | 1,024 | 829 | - | - |
| ឆ្នាំ2008 | 107 | 78 | 56 | 50 | 51 | 28 | - | - |
| **សរុប 2008-2017** | **184,219** | **137,850** | **135,305** | **106,163** | **48,860** | **31,651** | **54** | **36** |

## ១.៣.២. ក្រាហ្វិចស្ថានភាពហានិភ័យការងារ ឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧

*ក្រាហ្វិកទី៤. ចំនួនកម្មករនិយោជិតបានចុះបញ្ជិកា និងចំនួនហានិភ័យការងារ (នាក់)*




តាមក្រាហ្វិកខាងលើបានបង្ហាញឱ្យឃើញថា កម្មករជួបហានិភ័យការងារតាមឆ្នាំនីមួយៗមានការកើនឡើងជារៀងរាល់ឆ្នាំ ស្របទៅនឹងកំណើននៃចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកា។

*ក្រាហ្វិកទី៥. ស្ថានភាពហានិភ័យការងារតាមប្រភេទ និងកម្រិតរបួស(នាក់)*



ស្ថានភាពហានិភ័យការងារមានការកើនឡើង ស្របនឹងការកើនឡើងនៃចំនួនកម្មករនិយោជិតដែលបានចុះបញ្ជិកា។

### ១.៣.៣. ការចំណាយតាមប្រភេទតាវកាលិក

តាមរយៈការទាមទារតាវកាលិកពីជនរងគ្រោះ ប.ស.ស បានចេញសេចក្ដីសម្រេចផ្ដល់តាវកាលិកហានិភ័យការងារ ដល់កម្មករនិយោជិតដែលរងគ្រោះ ចំនួន ២០១ ៧៩៧(ដងនាក់) សម្រាប់ការព្យាបាលនៅតាមមន្ទីរពេទ្យ និងការថែទាំ, ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន, ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍, ឧត្តរជីវី, វិភាជន៍បូជាសព តាវកាលិកអ្នកចាំថែរក្សា និងចេញសេចក្ដីសម្រេចទូទាត់ថ្លៃព្យាបាលវេជ្ជសាស្ត្រជូនមន្ទីរពេទ្យផ្លូវការ និងមន្ទីរពេទ្យក្រៅផ្លូវការ និងសេវាស្តារនីតិសម្បទា សរុបចំនួន ៧៦,៦៤ ប៊ីលានរៀល។

**តារាងទី ០៩ ការចំណាយតាមប្រភេទតាវកាលិកហានិភ័យការងារ (គិតប៊ីលានរៀល)**

| ល.រ | ក. ប្រភេទតាវកាលិកហានិភ័យការងារ | ឆ្នាំ2008 | ឆ្នាំ2009 | ឆ្នាំ2010 | ឆ្នាំ2011 | ឆ្នាំ2012 | ឆ្នាំ2013 | ឆ្នាំ2014 | ឆ្នាំ2015 | ឆ្នាំ2016 | ឆ្នាំ2017 |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | តាវកាលិកព្យាបាល | - | 0.32 | 0.74 | 1.14 | 1.17 | 1.25 | 2.50 | 2.01 | 2.46 | 2.10 |
| ២ | តាវកាលិកថែទាំ | - | 0.00 | 0.02 | 0.04 | 0.03 | 0.04 | 0.07 | 0.12 | 0.17 | 0.19 |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពបណ្ដោះអាសន្ន | 0.00 | 0.13 | 0.36 | 0.57 | 0.56 | 0.77 | 1.11 | 1.92 | 2.55 | 2.39 |
| ៤ | តាវកាលិក.អចិន្ត្រៃយ៍ក្រោម ២០% *(វិភាជន៍)* | - | 0.01 | 0.04 | 0.05 | 0.05 | 0.14 | 0.09 | 0.18 | 0.41 | 0.53 |
| ៥ | តាវកាលិក.អចិន្ត្រៃយ៍ចាប់ពី ២០% *(ធនលាភ)* | - | 0.00 | 0.01 | 0.01 | 0.06 | 0.11 | 0.16 | 0.30 | 0.47 | 0.71 |
| ៦ | វិភាជន៍បូជាសព | - | 0.02 | 0.04 | 0.08 | 0.24 | 0.39 | 0.43 | 0.75 | 0.67 | 0.84 |
| ៧ | តាវកាលិកឧត្តរជីវី *(ធនលាភ)* | - | 0.00 | 0.03 | 0.08 | 0.12 | 0.24 | 0.40 | 0.70 | 1.11 | 1.60 |
| ៨ | តាវកាលិកអ្នកចាំថែរក្សា | - | - | - | - | 0.00 | 0.00 | 0.01 | 0.03 | 0.04 | 0.06 |
| ៩ | សេវាស្តារនីតិសម្បទា (បុននីតិសម្បទា) | - | - | - | - | 0.00 | 0.01 | 0.01 | 0.04 | 0.09 | 0.06 |
| | សរុប (ក) | 0.00 | 0.48 | 1.23 | 1.97 | 2.24 | 2.97 | 4.78 | 6.05 | 7.96 | 8.47 |
| ល.រ | ខ. ប្រភេទមូលដ្ឋានសុខាភិបាល | | | | | | | | | | |
| ១ | មន្ទីរពេទ្យផ្លូវការ | 0.01 | 0.59 | 1.19 | 2.12 | 2.44 | 3.27 | 4.01 | 5.01 | 6.42 | 8.31 |
| ២ | មន្ទីរពេទ្យក្រៅផ្លូវការ | - | - | - | - | 0.38 | 0.69 | 0.76 | 1.09 | 1.44 | 2.75 |
| | សរុប (ខ) | 0.01 | 0.59 | 1.19 | 2.12 | 2.82 | 3.95 | 4.77 | 6.10 | 7.86 | 11.06 |
| | សរុបរួម (ក+ខ) | 0.01 | 1.08 | 2.42 | 4.09 | 5.06 | 6.92 | 9.55 | 12.15 | 15.83 | 19.53 |
| | សរុបចំណាយ 2008-2017 | 76.64 | | | | | | | | | |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម ឆ្នាំ 2008 ដល់ឆ្នាំ2017

ការផ្ដល់តាវកាលិកនេះ ដោយសារការកើនឡើងនូវចំនួនគ្រោះថ្នាក់ការងារស្របគ្នានឹងការកើនឡើងកម្មករនិយោជិតដែលបានចុះបញ្ជិកា។

### ១.៣.៤. ការវាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

គណៈកម្មការវេជ្ជសាស្ត្រ បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព, យុត្តិធម៌ មនសិការ វិជ្ជាជីវៈ និងកសាងបានជំនឿទុកចិត្តពីសំណាក់មជ្ឈដ្ឋានទូទៅ និងសមាជិករបស់ ប.ស.ស ជាពិសេសពីនិយោជកជាម្ចាស់សហគ្រាស គ្រឹះស្ថាន មកលើការអនុវត្តរបស់ ប.ស.ស តាមរយៈការចូលរួមបង់ភាគទានធានារ៉ាប់រងហានិភ័យការងារជូនកម្មករនិយោជិត ហើយវាក៏បានជម្រុញឱ្យពួកគេផ្ដល់ព័ត៌មានពិតពីចំនួនកម្មករនិយោជិត និងពីចំនួនប្រាក់ខែរបស់ពួកគេ ដើម្បីជៀសវាងការបាត់បង់អត្ថប្រយោជន៍ដែលមានចែងនៅក្នុងច្បាប់។

*ក្រាហ្វិកទី៦. ការវាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍*




## ១.៤. ការខារស្តារនីតិសម្បទា

អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ការងាររហូតដល់ពិការភាព ត្រូវទទួលបានសេវាស្តារនីតិសម្បទា (បុននីតិសម្បទា)។ សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ប.ស.ស បាននិងកំពុងផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ តាមរយៈការផ្តល់នូវអវយវៈសិប្បនិម្មិត រណប ឧបករណ៍ជំនួយ ការ-ព្យាបាលដោយចលនា និងសេវាផ្នែកវេជ្ជសាស្ត្រមួយចំនួនទៀត ព្រមទាំងបានសម្របសម្រួលផ្តល់សេវាបណ្តុះ-បណ្តាលវិជ្ជាជីវៈ ដល់សមាជិកដែលទទួលរងគ្រោះថ្នាក់ការងាររហូតដល់ពិការភាពបានមួយចំនួនគួរឱ្យកត់សំគាល់។ ដើម្បីផ្តល់សេវាស្តានីតិសម្បទាដល់សមាជិកឱ្យបានកាន់តែមានប្រសិទ្ធភាព និងព្រមទាំងចូលរួមចំណែកលើកកម្ពស់ដល់វិស័យពិការភាពនៅកម្ពុជាផងដែរនោះ បេឡាជាតិរបបសន្តិសុខសង្គម បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ និងស្ថាបនពាក់ព័ន្ធនានា រៀបចំយន្តការពង្រឹង និងពង្រីកការផ្តល់សេវាស្តានីតិសម្បទានៅក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជួយសម្របសម្រួលរកការងារ និងសេវាសង្គមនានា។

ទន្ទឹមនឹងការយកចិត្តទុកដាក់លើការងារស្តានីតិសម្បទា នៅក្នុងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ប.ស.ស ក៏កំពុងរៀបចំយន្តការផ្តល់សេវាស្តានីតិសម្បទានៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពផងដែរ ដែលការផ្តល់សេវាស្តានីតិសម្បទានៅក្នុងរបបសន្តិសុខសង្គមទាំងពីរ នឹងត្រូវបានដាក់ឱ្យអនុវត្តពេញលេញនៅឆ្នាំ២០១៨ នេះ។ សម្រាប់ការងារស្តានីតិសម្បទា នៅឆ្នាំ២០១៧ កន្លងមក សម្រេចបាន៖

- សហការជាមួយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មតាមបណ្តារាជធានី-ខេត្ត ផ្តល់សេវាស្តារនីតិ-សម្បទា ដល់សមាជិកដែលទទួលរងគ្រោះថ្នាក់ការងាររហូតដល់ពិការភាពបានមួយចំនួន
- សហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលជនពិការបន្ទាយព្រាប ចុះសម្ភាសសមាជិកដែលទទួលរងពិការភាពដល់លំនៅដ្ឋាន និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមដាន ទំនាក់ទំនង សួរសុខទុក្ខ និងពិនិត្យស្ថានភាពរបស់សមាជិក ដើម្បីផ្តល់សេវាស្តារនីតិ-សម្បទា
- សហការជាមួយក្រុមហ៊ុន Exceed ផ្តល់សេវាស្តារនីតិសម្បទា ដល់សមាជិក ប.ស.ស

- សហការជាមួយមូលនិធិជនពិការ និងស្ថាបនពាក់ព័ន្ធ ដើម្បីជម្រុញការផ្តល់សេវាស្តារនីតិសម្បទាដល់សមាជិកឱ្យបានកាន់តែមានប្រសិទ្ធភាព
- រៀបចំសេចក្តីព្រាងប្រកាស ស្តីពីសេវាស្តារនីតិសម្បទាសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- សហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) អង្គការសុខភាពពិភពលោក (WHO) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាឡឺម៉ង់ (GIZ) ដើម្បីរៀបចំយន្តការផ្តល់សេវាស្តារនីតិសម្បទា។
- ចូលរួមវគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាស្តីពីការផ្តល់សេវាស្តារនីតិសម្បទានៅក្រៅប្រទេស
- សិក្សាស្រាវជ្រាវ និងរៀបចំបែបបទ នីតិវិធី ដាក់ឱ្យដំណើរការផ្តល់សេវាស្តារនីតិសម្បទា។

# ២. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

## ២.១. ការចារបញ្ជិកា និងភាគទាន

### ២.១.១. ការចារបញ្ជិកា (ការកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ)

ផ្អែកតាមប្រកាសលេខ០៩៣ កប/ប្រក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងសេចក្តីជូនដំណឹងលេខ ១២៧ កប/ស.ជ.ណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុង ប.ស.ស ក្នុងទិសដៅនេះ ប.ស.ស បានកំណត់ការអនុវត្តដោយផ្តើមចេញពីសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងជាបន្តបន្ទាប់ឈានទៅកាន់ខេត្តដទៃទៀត ស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង។

ប.ស.ស បានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញត្រឹមឆ្នាំ២០១៧ នេះ បានចំនួន ៣ ២៧១សហគ្រាស មានកម្មករនិយោជិតចំនួន ១ ១២១ ៤០៩នាក់ ស្រី ៨៤៨ ១២៦នាក់។

**តារាងទី ១០. កំណត់អត្តសញ្ញាណកម្មករនិយោជិតជាថ្មី**

| បរិយាយ | កំណត់អត្តសញ្ញាណកម្មករនិយោជិតជាថ្មី | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | | ថ្នាក់កណ្តាល (រាជធានីភ្នំពេញ) | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| គិតត្រឹមឆ្នាំ2017 | 3,271 | 1,121,409 | 848,126 | 1,709 | 599,080 | 451,618 | 1,562 | 522,329 | 396,508 |
| បច្ចុប្បន្នភាពសហគ្រាស និងកម្មករនិយោជិត ឆ្នាំ2017 | 8,507 | 1,182,849 | 787,547 | 4,435 | 627,637 | 389,029 | 4,072 | 555,212 | 398,518 |
| ផលធៀប (%) | 38.45% | 94.81% | 107.69% | 38.53% | 95.45% | 116.09% | 38.36% | 94.08% | 99.50% |

ផ្អែកតាមតារាងទី១៨ ការធ្វើផលធៀបរវាងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញធៀបនឹងបច្ចុប្បន្នភាពសហគ្រាសចុះបញ្ជិកា សម្រេចបាន ៣៨,៤៥ភាគរយ។

### ២.១.២. ការទារភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលភាគទាន និងបង់ភាគទាន មក ប.ស.ស។ អត្រាភាគទានរបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយ និងកម្មករនិយោជិតក៏ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយដែរ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

| តារាងទី ១១ ភាគទាន គម្រោង ថែទាំសុខភាពដោយស្ម័គ្រចិត្ត (HIP) | |
|---|---|
| ឆ្នាំ 2016 | 0.12 |
| ឆ្នាំ 2015 | 0.61 |
| ឆ្នាំ2014 | 0.66 |
| ឆ្នាំ 2013 | 0.11 |
| សរុបភាគទាន (ប៊ីលានរៀល) (ក) | 1.50 |
| **ភាគទាន ផ្នែក ថែទាំសុខភាព** | |
| ឆ្នាំ 2017 | 154.75 |
| ឆ្នាំ 2016 | 17.05 |
| សរុបភាគទាន (ប៊ីលានរៀល) (ខ) | 171.80 |
| សរុបភាគទាន (ប៊ីលានរៀល) (ក) + (ខ) | 173.30 |

**តារាងទី ១១.១ សហគ្រាស គ្រឹះស្ថាន បានបង់ភាគទាន និងមិនបានបង់ភាគទាន**

| **បរិយាយ** | សហគ្រាស ជាប់ភាគទាន (មធ្យមភាគ) | សហគ្រាស បានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | | ភាគទានសរុប (ប៊ីលានរៀល) | សហគ្រាស មិនបានបង់ ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | | សរុប | ស្រី |
| ឆ្នាំ ២០១៧ | 626 | 610 | 608,965 | 505,605 | 154.75 | 16 | 9,229 | 7,456 |
| ឆ្នាំ ២០១៦ | 335 | 282 | 265,761 | 222,247 | 0.18 | 53 | 37,577 | 3,009 |
| បម្រែបម្រួល (± %) | 86.94% | 116.31% | 129.14% | 127.50% | 85966.01% | -69.34% | -75.44% | 147.78% |

នៅក្នុងឆ្នាំ២០១៧ ប.ស.ស បានដាក់ឲ្យជាប់ភាគទាន ចំនួន ៦២៦សហគ្រាស ក្នុងនោះសហគ្រាសបានបង់ភាគទាន មានចំនួន ៦១០សហគ្រាស មានកម្មករនិយោជិតចំនួន ៦០៨ ៩៦៥នាក់ ស្រី ៥០៥ ៦០៥នាក់។

### ២.២. ការទារអធិការកិច្ច និងកិច្ចការនីតិកម្ម

*ក្រាហ្វិកទី៧. ការចុះអធិការកិច្ចផ្នែកថែទាំសុខភាព*




- ចុះទៅសម្របសម្រួល (ចុះបើកផ្លូវ)

- សហការរចុះទៅពន្យល់ណែនាំពីនីតិវិធីចុះបញ្ជិកា
- សហការចុះចែកលិខិតឱ្យសហគ្រាស គ្រឹះស្ថានជាប់ភាគទាន
- សហការចុះទៅពន្យល់ណែនាំពីតាវកាលិកថែទាំសុខភាព និងការបង់ភាគទាន

## ២.៣. ការផ្តល់សេវាតាវកាលិក

ដើម្បីឱ្យកម្មករទទួលបានសេវាដែលនៅជិតកន្លែងការងារ និងលំនៅស្ថាន ក្នុងដំណាក់កាលនេះ ប.ស.ស បានពង្រីកវិសាលភាពចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានី-ខេត្ត គិតត្រឹមឆ្នាំ២០១៧ ចំនួន ១ ២៩៥ មូលដ្ឋាន រួមមានមន្ទីរពេទ្យថ្នាក់ជាតិចំនួន០៤ មន្ទីរពេទ្យបង្អែកចំនួន ១០៧ មណ្ឌល-សុខភាព ចំនួន ១ ១៦៩មូលដ្ឋាន មន្ទីរពេទ្យឯកជនចំនួន ១៥មូលដ្ឋាន។

### ២.៣.១. សមាជិកនៅប្រើប្រាស់សេវា

| តារាងទី១២ សមាជិកប្រើប្រាស់ (HIP) | | | | |
|---|---|---|---|---|
| ឆ្នាំ2016 | ឆ្នាំ2015 | ឆ្នាំ2014 | ឆ្នាំ2013 | សរុប |
| 2,224 | 11,466 | 10,784 | 2,564 | 27,038 |
| ( គិតជាមធ្យមភាគ) | | | | |
| 185 | 956 | 899 | 214 | 563.29 |

| តារាងទី ១៣ ចំនួនសមាជិកទៅទទួលសេវាផ្នែកថែទាំសុខភាព | | |
|---|---|---|
| បរិយាយ | នាក់ | ដងនាក់ |
| ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ឆ្នាំ2017 | 218,697 | 559,647 |

### ២.៣.២. ការចំណាយតាវកាលិក

| តារាងទី ១៤ ចំណាយ គម្រោងថែទាំសុខភាពដោយស្ម័គ្រចិត្ត (HIP) | |
|---|---|
| ឆ្នាំ 2016 | 0.19 |
| ឆ្នាំ 2015 | 0.32 |
| ឆ្នាំ2014 | 0.29 |
| ឆ្នាំ 2013 | 0.04 |
| សរុបភាគទាន (ប៊ីលានរៀល) (ក) | 0.85 |
| ចំណាយ ផ្នែកថែទាំសុខភាព | |
| ឆ្នាំ 2017 | 26.54 |
| ឆ្នាំ 2016 | 0.01 |
| សរុបភាគទាន (ប៊ីលានរៀល) (ខ) | 26.55 |
| សរុបភាគទាន (ប៊ីលានរៀល) (ក) + (ខ) | 27.40 |

## ៣. ជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

ការរៀបចំបង្កើតឱ្យមានរបបប្រាក់សោធន សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជនបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលចំពោះអនាគត នៃកម្លាំងពលកម្មសកម្ម នាពេលបច្ចុប្បន្ន និងម្យ៉ាងទៀតក៏ជាការរួមចំណែកលើកកម្ពស់ផលិតភាពពលកម្មផងដែរ ព្រោះថាតាមរយៈយន្តការនេះកម្មករនិយោជិត ដែលជាកម្លាំងពលកម្មសកម្ម នឹងមានភាពកក់ក្តៅក្នុងចិត្តចំពោះអនាគតរបស់ខ្លួនទោះបីជាកំពុងធ្វើការក្នុងវិស័យឯក-ជនក្តី ក៏ពួកគេអាចមានលទ្ធភាពរស់នៅដោយខ្លួនឯងបាននៅពេលជរាភាព ដោយមិនអាស្រ័យទាំងស្រុងលើការចិញ្ចឹមជីវិតពីកូនចៅនោះឡើយ។ ចំណុចនេះគឺជាផ្នែកមួយលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ជនចាស់ជរា។

ផ្នែកប្រាក់សោធននេះ ត្រូវបានថ្នាក់ដឹកនាំកំណត់ដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩ ដែលបច្ចុប្បន្ន ប.ស.ស បាននិងកំពុងសិក្សាបទដ្ឋានគតិយុត្ត ដែលឈានដល់ការរៀបចំសមិទ្ធិលទ្ធភាពដាក់ឱ្យដំណើរការដោយការរំពឹងទុក និងគ្មានផលប៉ះពាល់។

## ខ. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីត-យុទ្ធជន

សម្រាប់ការរៀបចំដាក់ឱ្យដំណើរការផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីយុទ្ធជន ក្រុមការងារបានរៀបចំលិខិតបទដ្ឋានគតិយុត្ត បែបបទ និងនីតិវិធី ការងារដូចខាងក្រោម៖

- ព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- រៀបចំសេចក្តីព្រាងលិខិតគតិយុត្តផ្សេងៗ

ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីយុទ្ធជន ត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨។ ដោយឡែកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ បច្ចុប្បន្នក្រុមការងាររៀបចំបាននិងកំពុងសិក្សាបទដ្ឋានគតិយុត្ត ដែលឈានដល់ការរៀបចំសមិទ្ធិលទ្ធភាពដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩ ខាងមុខ។

## គ. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

អនុលោមតាមប្រកាសអន្តរក្រសួង រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល លេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករ និយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។ ប.ស.ស ទទួលបន្ទុកគ្រប់គ្រង និងចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ និងបើកប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនសម្រាប់កម្មករនិយោជិតក្នុង និងក្រៅប្រព័ន្ធ។

### ១. ការងារចុះបញ្ជិកា

**តារាងទី ១៥** សហគ្រាសចុះបញ្ជិកា និងសមាជិកសរុបក្រៅប្រព័ន្ធ (មូលនិធិសមធម៌)

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2017 | 21,379 | 184,436 | 27,665 | 15,513 | 87,575 | 13,136 | 5,866 | 96,861 | 14,529 |

**២. ការផ្តល់តាវកាលិក**

កម្មករនិយោជិតក្រៅប្រព័ន្ធ ត្រូវប្រើប្រាស់សេវាតាមមូលដ្ឋានសុខាភិបាលពីថ្នាក់បឋម នៅមូលដ្ឋានសុខាភិបាលថ្នាក់ទាបទៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត។

**៣. ការបើកប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន**

ការបើកប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធ ត្រូវដាក់ឱ្យអនុវត្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨។

**ឃ. ការងារគាំទ្រការអនុវត្ត**

**១. ការងាររៀបចំគោលនយោបាយ និងលិខិតគតិយុត្ត**

ការកើនឡើងនូវទំហំការងារ ចំនួនសមាជិក ស្ថានភាពនៃការរីកចម្រើនសេដ្ឋកិច្ចសង្គម និងតម្រូវការនៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ និយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន ប.ស.ស រហូតដល់ឆ្នាំ២០១៧ នេះ បានខិតខំប្រឹងប្រែងបំពេញការងារទ្វេឡើងដោយបានរៀបចំពង្រឹង ពង្រីក និងអភិវឌ្ឍន៍គោលនយោបាយរបបសន្តិសុខសង្គម តាមរយៈការរៀបចំផែនការរយៈពេលវែង ដែលមានលក្ខណៈស៊ីជម្រៅ និងការកសាងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ដើម្បីធានាក្នុងការផ្តល់សេវាសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាពទាន់ ពេលវេលា និងឆ្លើយតបតាមតម្រូវការ។

- **កិច្ចប្រជុំរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត**
  - ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំ របស់បេឡាជាតិរបបសន្តិសុខសង្គម
  - ពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបាន របស់បេឡាជាតិរបបសន្តិសុខសង្គម
  - ពិនិត្យ និងអនុម័តផែនការចំណូល ចំណាយថវិកា របស់បេឡាជាតិរបបសន្តិសុខសង្គម
  - ពិនិត្យ ពិភាក្សា និងកែសម្រួលខ្លឹមសារសេចក្តីព្រាងប្រកាស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម
  - ពិនិត្យ ពិភាក្សា និងកែសម្រួលខ្លឹមសារសេចក្តីព្រាងប្រកាស ស្តីពីការកំណត់អត្រាភាគទាន បែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព
- **កិច្ចប្រជុំរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ**
  - ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
  - ពិនិត្យ និងកែសម្រួលលើខ្លឹមសារសេចក្តីព្រាង អនុក្រឹត្យស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

## ២. ការងារគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស

### ២.១. ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

#### ២.១.១. ការងាររដ្ឋបាល

ការងាររដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងឯកសារ ការផ្គត់ផ្គង់ និងការគ្រប់គ្រងមន្ត្រី បុគ្គលិក ដើម្បីធានាបាននូវការអនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។ នៅឆ្នាំ ២០១៧ នេះ រដ្ឋបាលរបស់ ប.ស.ស សម្រេចបាន៖

**ក. ផ្នែកគ្រប់គ្រងលិខិត**

- គ្រប់គ្រងលិខិតចូល
- គ្រប់គ្រងលិខិតចេញ

**ខ.ការងារកសាងលិខិត**

- រៀបចំទូទាត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ជូនមន្ត្រី និងបុគ្គលិក
- រៀបចំបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដល់បុគ្គលិក
- រៀបចំតម្លើងកម្រិតមុខងារ និងប្រាក់កម្រៃលើកទឹកចិត្ត ជូនមន្ត្រីរាជការ
- រៀបចំតម្លើងឋានន្តរស័ក្តិ ថ្នាក់តាមវេន និងតាមសញ្ញាបត្រ រួមទាំងប្រាក់កម្រៃលើកទឹកចិត្តជូនមន្ត្រីរាជការ ប្រចាំ ប.ស.ស
- រៀបចំតម្លើងឋានន្តរស័ក្តិ ថ្នាក់តាមវេន និងប្រាក់កម្រៃលើកទឹកចិត្ត រួមទាំងរំលឹកប្រាក់កម្រៃលើកទឹកចិត្តជូនមន្ត្រីរាជការ ប.ស.ស
- រៀបចំវាយតម្លៃមន្ត្រីរាជការស្នើសុំគ្រឿងឥស្សរិយយស ប្រចាំ ប.ស.ស
- រៀបចំគោលការណ៍ស្នើសុំប្រជុំពិភាក្សាលើការកំណត់ចំនួនជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិក ជាប់កិច្ចសន្យា ប្រចាំ ប.ស.ស
- កែសម្រួល និងផ្តល់ប្រាក់កម្រិតមុខងារ ជូនមន្ត្រីរាជការ ដែលបានទទួលការតែងតាំងពីបេឡាជាតិរបបសន្តិសុខសង្គម
- រៀបចំឯកសារបញ្ចូលបុគ្គលិកសាកល្បងការងារ
- បានដាក់បញ្ចូលបុគ្គលិកឱ្យពេញសិទ្ធិ

#### ២.១.២. ការងារហិរញ្ញវត្ថុ

ការងារគណនេយ្យ និងកិច្ចការហិរញ្ញវត្ថុ របស់ ប.ស.ស ប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារទាំងស្រុងពោលគឺរាល់កិច្ចដំណើរការនៃការគ្រប់គ្រងចំណូល និងចំណាយ មានជាអាទិ៍ ការប្រមូលភាគទានពីសហគ្រាស គ្រឹះស្ថាន, ការបង់ប្រាក់ពិន័យ, ការចំណាយតាវកាលិកដល់កម្មករនិយោជិតដែលរងហានិភ័យការងារ និងការចំណាយរដ្ឋបាល ត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់តាមប្រព័ន្ធធនាគារ ក្នុងនោះមានធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារឯកទេសរីង ក្នុងការប្រមូលភាគទាន បើកផ្តល់តាវកាលិក និងការ

រក្សាមូលនិធិបម្រុងសន្តិសុខសង្គម ក្នុងគោលដៅធានាពីប្រសិទ្ធភាព និងគណនេយ្យភាព។ ក្នុងដំណើរការនៃកិច្ចប្រតិបត្តិការ ប.ស.ស បានអនុវត្តនូវការងារសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

- រៀបចំផែនការចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ (លើកទិសដៅអនុវត្ត)
- រៀបចំរបាយការណ៍ចំណូល និងចំណាយសាច់ប្រាក់លម្អិតប្រចាំខែក្នុងឆ្នាំ២០១៧
- កត់ត្រាចំណូលភាគទានប្រចាំខែ ដែលបានមកពីការប្រមូលភាគទានតាមរោងចក្រ សហគ្រាស នីមួយៗនៅក្នុង Account Receivable
- កត់ត្រាចំណាយប្រចាំថ្ងៃនៅក្នុង Journal Entry
- កត់ត្រាចំណាយជំពាក់ជាសាច់ប្រាក់ប្រចាំខែ សម្រាប់អង្គភាពផ្គត់ផ្គង់ដូចជាថ្លៃព្យាបាលនៅតាមមន្ទីរពេទ្យនីមួយៗ និងតាវកាលិកធនលាភដែលសមាជិក ប.ស.ស ទទួលបានក្នុង Account Payable
- រៀបចំអត្រាប្តូរប្រាក់សម្រាប់ភាគទានប្រចាំខែនីមួយៗ
- ពិនិត្យចំណាយផ្សេងៗដូចជា ចំណាយបេសកកម្ម, ចំណាយរដ្ឋបាល, ចំណាយបង្ការហានិភ័យការងារ និងចំណាយតាវកាលិក
- រៀបចំបង់ពន្ធលើប្រាក់លើកទឹកចិត្តប្រចាំខែនីមួយៗ
- រៀបចំបញ្ជីបើកប្រាក់បៀវត្សប្រចាំខែនីមួយៗ
- ផ្ទៀងផ្ទាត់របាយការណ៍ធនាគារជាមួយសៀវភៅបេឡា។

## ២.២. កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស ជាការងារមួយសំខាន់នៅក្នុងការអភិវឌ្ឍអង្គភាព និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងផ្នែកដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីធានានូវនិរន្តរភាពនៃកិច្ចដំណើរការរបស់អង្គភាព លើការរៀបចំផែនការ បែបបទ និងនីតិវិធីការងារ ក៏ដូចជាការអភិវឌ្ឍនូវចំណេះដឹងការដកស្រង់ និងផ្លាស់ប្តូរបទពិសោធន៍ការងារថ្មីៗ។ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាការចូលរួមចំណែកនៅក្នុងសកម្មភាពការងារសង្គមទាំងមូលឱ្យមានការរីកចម្រើនផងដែរ ដែលថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រី ប.ស.ស បានចូលរួមកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងនៅក្នុងប្រទេសនិងក្រៅប្រទេស ដូចខាងក្រោម៖

### ២.២.១. ការបណ្តុះបណ្តាលធនធានមនុស្ស

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធី និងដំណើរការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពមានមន្ត្រី
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីនីតិវិធី នៃការចុះបញ្ជិកា កម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដល់មន្ត្រី និងបុគ្គលិក ប.ស.ស តាមសាខាខេត្ត/ខណ្ឌ
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី Administration of old age penson ដល់មន្ត្រីថ្នាក់ដឹកនាំ និងថ្នាក់ការិយាល័យនៃ ប.ស.ស

- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីនីតិវិធីនៃការចុះបញ្ជិកាកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព អនុគណនី៦១១២, អនុកម្មវិធីទី៤ ដល់មន្រ្តី និងបុគ្គលិក
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបបសន្តិសុខ-សង្គម តាមបណ្តាសាខាខេត្ត-ខណ្ឌ ដល់មន្រ្តី និងបុគ្គលិក
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីនីតិវិធីនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ដល់បុគ្គលិកទើបតែចូលថ្មី។

### ២.២.២. ការងារក្នុងប្រទេស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស ប.ស.ស បានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងធ្វើបច្ចុប្បន្នភាពការងារផ្ទៃក្នុងដល់មន្រ្តី និងបុគ្គលិកជាប្រចាំរៀងរាល់ឆ្នាំ។ ថ្នាក់ដឹកនាំ មន្រ្តី និងបុគ្គលិក នៃ ប.ស.ស បានរៀបចំ និងចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពិភាក្សាការងារការរៀបចំផែនការអភិវឌ្ឍន៍ និងសិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងតាមបណ្តាក្រសួង អង្គការ និងស្ថាប័នពាក់ព័ន្ធនានានៅទូទាំងប្រទេសជាច្រើនលើក នៅក្នុងឆ្នាំ២០១៧ រួមមាន៖

- ចូលរួមសិក្ខាសាលាលើកកម្ពស់ការយល់ដឹងអំពីបទប្បញ្ញត្តិ និងប្រកាសទាក់ទងនឹងលក្ខ-ខណ្ឌការងារសម្រាប់កម្មករការងារតាមផ្ទះ នៅសណ្ឋាគារ Himawari
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការវិភាគទិន្នន័យ ស្តីពីបទពិសោធន៍ស្រ្តី ដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សាផ្សេងៗ នៅសណ្ឋាគារឡែនស្កេប
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី០២ លើសេចក្តីព្រាងបឋមច្បាប់ស្តីពីការពារសាក្សី និងច្បាប់ស្តីពី ការពារបុគ្គលរាយការណ៍ នៅអង្គភាពប្រឆាំងអំពើពុករលួយ
- ចូលរួមប្រជុំពិភាក្សាពាក់ព័ន្ធ នឹងការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៦ និងលើកទិសដៅអនុវត្តឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីការ រៀបចំគិលានដ្ឋានសហគ្រាស គ្រឹះស្ថាន នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី សិទ្ធិរបស់យុវជននៅកន្លែងការងារ នៅទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ចូលរួមសិក្ខាសាលាស្តីពី ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ នៅសណ្ឋាគារសុខាភ្នំពេញ
- ចូលរួមប្រជុំពិនិត្យវាយតម្លៃដំឡើងឋានន្តរស័ក្តិ និងថ្នាក់ សម្រាប់ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ចូលរួមសិក្ខាសាលាស្តីពី ការបញ្ជ្រាបការយល់ដឹងពីប្រព័ន្ធ FMIS នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យមើលឡើងវិញនូវលទ្ធផលប្រចាំឆ្នាំនៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី ការវាយតម្លៃហានិភ័យ (Actuarial Study) សម្រាប់ប្រព័ន្ធសោធននៅកម្ពុជា នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលាស្តីពី ដំណើរការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងាររយៈពេល០៣ឆ្នាំ(២០១៩-២០១៧)នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាត្រីភាគី ពិនិត្យប្រចាំឆ្នាំស្តីពី កម្មវិធីការងារសមរម្យសម្រាប់កម្ពុជា (២០១៦-២០១៨) នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី វិទ្យាសាស្ត្រសេដ្ឋកិច្ចសម្រាប់អ្នកដែលមិនមែនជាអ្នកសេដ្ឋកិច្ច នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពដំណាក់កាលទី០៣ នៅសណ្ឋាគារ OC Boutique ខេត្តព្រះសីហនុ
- ចូលរួមវគ្គបណ្តុះបណ្តាលពិសេស នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមកិច្ចប្រជុំអនុគណៈកម្មការទីមួយស្តីពីការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមកិច្ចប្រជុំស្តីពី កម្មវិធីបណ្តុះបណ្តាលកម្មសិក្សាបច្ចេកទេសជាមួយភាគីជប៉ុន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី លទ្ធផលនៃការសិក្សាពីលទ្ធភាពគ្របដណ្តប់ក្រុមប្រជាជនសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី
- ចូលរួមសិក្ខាសាលាស្តីពី ត្រីភាគីត្រៀមថ្នាក់ជាតិ នៅសណ្ឋាគារ Angkor Paradise
- ចូលរួមសិក្ខាសាលាស្តីពី បច្ចុប្បន្នភាពនៃគោលបំណង និងគោលដៅសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅសណ្ឋាគារកាំបូឌីយ៉ាណា
- ចូលរួមសិក្ខាសាលាត្រីភាគីស្តីពី ពិនិត្យប្រចាំឆ្នាំ ស្តីពីកម្មវិធីការងារសមរម្យសម្រាប់កម្ពុជា នៅសណ្ឋាគារភ្នំពេញ

### ២.២.៣. ការងារក្រៅប្រទេស

ក្រៅពីការងារលើកកម្ពស់ធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការក្នុងប្រទេស ការទំនាក់ទំនងក្រៅប្រទេសជាការងារមួយដ៏សំខាន់ នៅក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍បរទេស

នានា និងការធ្វើសមាហរណកម្មវិស័យសន្តិសុខសង្គមរបស់កម្ពុជាទៅក្នុងតំបន់ ដើម្បីឱ្យមានការផ្លាស់ប្តូរនូវបទ-ពិសោធន៍ បច្ចេកទេសការងារថ្មីៗ យកមកធ្វើការអភិវឌ្ឍនៅក្នុងប្រទេស។ ឆ្នាំ២០១៧ នេះ ប.ស.ស បានបំពេញនូវការងារក្រៅប្រទេសសំខាន់ៗមួយចំនួនសម្រាប់វិស័យសន្តិសុខសង្គម ដូចខាងក្រោម៖

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយប្រាក់ឈ្នួល នៅសាធារណៈរដ្ឋកូរ៉េ
- សោធនជរាភាព នៅប្រទេសវៀតណាម
- ចូលរួមសិក្ខាសិលាស្តីពី ប្រសិទ្ធភាពនៃកម្មវិធីសន្តិសុខសង្គម នៅក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី នៅប្រទេសឥណ្ឌូណេស៊ី
- ចូលរួមសិក្ខាសិលាស្តីពី ភាពជាអ្នកដឹកនាំសម្រាប់ការគ្របដណ្តប់របបថែទាំសុខភាពជាសកល នៅប្រទេសជប៉ុន
- ចូលរួមទស្សនកិច្ចសិក្សាស្តីពី ប្រព័ន្ធផ្តល់ព័ត៌មានតាមទូរស័ព្ទ (Call Center) នៅ SSO ប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការធានារ៉ាប់រងសុខភាពសង្គម នៅសាធារណៈរដ្ឋកូរ៉េ
- ចូលរួមសិក្ខាសាលាស្តីពី ការទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ ដើម្បីឈានទៅការគ្របដណ្តប់សេវាសុខាភិបាលជាសកល នៅប្រទេសហ្គាណា
- ចូលរួមសន្និសិទសន្តិសុខសង្គមអន្តរជាតិស្តីពី អនាគតនៃការងារ នៅប្រទេសម៉ាឡេស៊ី
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៤ នៅប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីការរៀបចំប្រព័ន្ធសោធននិវត្តន៍ នៅប្រទេសអា-ឡឺម៉ង់
- ចូលរួមសន្និសិទជាន់ខ្ពស់អាស៊ានស្តីពីកិច្ចគាំពារសង្គម នៅប្រទេសហ្វីលីពីន
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសេវាស្តារនីតិសម្បទាសម្រាប់កម្មករពិការកាយសម្បទានៅប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីស្តីពី ការរៀបចំប្រព័ន្ធធានារ៉ាប់រងសុខភាពនៅប្រទេសអាឡឺម៉ង់
- ចូលរួមសិក្ខាសាលាស្តីពី យន្តការហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពសម្រាប់ធានារ៉ាប់រងសង្គម និងនិរន្តភាពនៃប្រព័ន្ធសោធនក្នុងអាស៊ាន នៅប្រទេសវៀតណាម
- ចូលរួមសិក្ខាសាលាអន្តរជាតិ ស្តីពីការពង្រីកការគ្របដណ្តប់សន្តិសុខសង្គមក្នុងសម័យ-កាល ដែលសេដ្ឋកិច្ចជួបប្រទះបញ្ហា នៅប្រទេសឥណ្ឌូណេស៊ី
- ចូលរួមកិច្ចប្រជុំកម្មវិធី អាទិភាពជាសកលរបស់អង្គការ ILO ស្តីពីការបង្កើតមូលដ្ឋានគាំពារសង្គមសម្រាប់ទាំងអស់គ្នា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស
- ចូលរួមកិច្ចប្រជុំពិភាក្សាលើកិច្ចព្រមព្រៀង ស្តីពីតាវកាលិកជរាភាពនៅទីក្រុងបាងកក ប្រ-ទេសថៃ

- ចូលរួមកិច្ចប្រជុំវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាពាក់ព័ន្ធ និងដំណើរការនៃមុខងាររបស់អង្គភាពត្រួតពិនិត្យ និងវាយតម្លៃគម្រោងធានារ៉ាប់រងសុខភាពនៅទីក្រុងសេអ៊ូល សាធារណៈរដ្ឋកូរ៉េ

## ២.៣. ការងារព័ត៌មានវិទ្យា

ប.ស.ស បានរៀបចំកិច្ចប្រតិបត្តិការងារ និងការគ្រប់គ្រងទិន្នន័យតាមរយៈបច្ចេកវិទ្យាព័ត៌មានវិទ្យាលើការងារចុះបញ្ជិកា, បង់ភាគទាន, ការផ្តល់តាវកាលិក, ការគ្រប់គ្រងវត្តមានមន្ត្រី និងការងារសំខាន់ៗមួយចំនួនទៀតសម្រេចបានលើការងារព័ត៌មានវិទ្យា ដូចខាងក្រោម៖

### ២.៣.១. ផ្នែក Programming

- កម្មវិធីចុះឈ្មោះបេក្ខជនប្រឡង
- អភិវឌ្ឍន៍កម្មវិធីស្តារនីតិសម្បទា
- កម្មវិធី NSSF Program
- កម្មវិធី NSSF Program v7.01
- កម្មវិធី (E-Form Web Application) សម្រាប់មន្ត្រីសាធារណៈ
- កម្មវិធី E-Form (Web Application) សម្រាប់កម្មករនិយោជិត
- កម្មវិធី HSPIS
- កម្មវិធីបញ្ជិកា និងភាគទានសម្រាប់សមាជិកក្រៅប្រព័ន្ធ
- កម្មវិធីបញ្ជិកានិងភាគទានសម្រាប់មន្ត្រីសាធារណៈ
- កម្មវិធីបញ្ជិកា និងភាគទាន
- កម្មវិធីរដ្ឋបាល
- អភិវឌ្ឍន៍កម្មវិធី HR System
- អភិវឌ្ឍន៍គេហទំព័រ ប.ស.ស ថ្មី
- គេហទំព័រ ប.ស.ស
- កម្មវិធីតាវកាលិក ( NEW NSSF Benefit )៖
  - ✓ ផ្នែកតាវកាលិក (ហានិភ័យការងារ)
  - ✓ ផ្នែកអង្កេតគ្រោះថ្នាក់ការងារ
  - ✓ ផ្នែកតាវកាលិក (ថែទាំសុខភាព)
  - ✓ ផ្នែកទូទាត់ចំណាយវេជ្ជសាស្ត្រទៅមន្ទីរពេទ្យ (គ្រោះថ្នាក់ការងារ)
  - ✓ ផ្នែកអធិការកិច្ច
- កម្មវិធីទាញទិន្នន័យទៅកាន់កម្មវិធី Sage Accpac (NSSF Sage)
- កម្មវិធី NSSF Sage Application
- កម្មវិធីស្វែងរកទិន្នន័យព័ត៌មានស្វែងរកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមរយៈ API
- អភិវឌ្ឍន៍កម្មវិធីណាត់មន្ទីរពេទ្យតាមអនឡាញ

- ប្រព័ន្ធណាត់មន្ទីរពេទ្យតាមអនឡាញតាមរយៈ Smartphone (IOS)
- កម្មវិធីស្វែងរកព័ត៌មានកម្មករនិយោជិតតាមរយៈ Smartphone (IOS)

## ២.៣.២. ផ្នែក Networking

- សហការជាមួយក្រុមហ៊ុន Online ដើម្បីដោះស្រាយបញ្ហា Link Failover
- ដោះស្រាយបញ្ហាតភ្ជាប់ទៅកាន់ Finger Print តាមបណ្ដារាជធានី-ខេត្ត
- ធ្វើការ Configure ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចប្រើប្រាស់ VOIP-PHONE តាមបណ្ដារាជធានី-ខេត្ត
- រៀបចំ PRTG ដើម្បីបន្ថែមព័ត៌មានមួយចំនួនទៀត (ID តាមក្រុមហ៊ុន ISP នីមួយៗ) ដើម្បីងាយស្រួលដល់ផ្នែកតំហែទាំធ្វើការទំនាក់ទំនងជាមួយក្រុមហ៊ុនផ្ដល់សេវាកម្ម
- ធ្វើការ Configure ដើម្បីអនុញ្ញាតឱ្យ Admin អាចទៅកាន់មន្ទីរពេទ្យ (ទាញទិន្នន័យក្នុង Finger Print )
- ដំឡើង Cisco Switch 2960-x សម្រាប់ភ្ជាប់ម៉ាស៊ីនមេ (Server Farm)
- រៀបចំបណ្ដាញតភ្ជាប់ជាមួយនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (VPN)
- សហការជាមួយក្រុមហ៊ុន RMO ដើម្បីត្រួតពិនិត្យលើឧបករណ៍ Juniper និងឧបករណ៍ Microtech របស់ក្រុមហ៊ុន SINET ក្នុងគោលបំណងធ្វើ Active/ Standby និងដើម្បីបង្កើតឈ្មោះអ្នកប្រើប្រាស់អ៊ីនធើណែតហើយបន្ថែមចូលក្រុមមួយៗ
- ធ្វើការ Configure NAT ដើម្បីតភ្ជាប់ទៅកាន់ DVR តាមសាខាខេត្ត-ខណ្ឌ
- ធ្វើការ Configure ASA 5505 សម្រាប់ភ្ជាប់បណ្ដាញនៅនាយកដ្ឋានអត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរ
- ធ្វើការ Configure NAT ក្នុង ឧបករណ៍ Juniper និងConfigure Access-list ក្នុង Cisco ASA 5505 ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់ក្នុងទូរស័ព្ទដៃអាចមើលកាម៉េរ៉ានៅតាមសាខារបស់ខ្លួនបាន
- ដំឡើងកម្មវិធី សម្រាប់មើលរូបភាព IVMS-4500 និង CatiEZ និង Configuration SNMP
- ធ្វើបច្ចុប្បន្នភាពដ្យាក្រាមបណ្ដាញនៅស្នាក់ការកណ្ដាល
- សហការជាមួយក្រុមតំហែរទាំរៀបចំបណ្ដាញខ្សែឡើងវិញ (រៀបចំដាក់ឈ្មោះសំគាល់លើខ្សែ ធ្វើការសាកល្បងភ្ជាប់ប្រព័ន្ធទិន្នន័យនីមួយៗ)
- ដោះស្រាយប្រព័ន្ធបណ្ដាញ (កំណត់អត្តសញ្ញណ) ដែលពុំអាចភ្ជាប់មកកាន់ប្រព័ន្ធបានចំពោះម៉ាស៊ីនកុំព្យូទ័រមួយចំនួន
- រៀបចំ សហការ ធ្វើការ កែសម្រួល ដំឡើង តបណ្ដាញ Network ផ្សេងៗ
- រៀបចំប្រជុំក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យាជាមួយសហគ្រាសស្ដីពីនីតិវិធី និងយន្តការនៃការផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- រៀបចំបិទបញ្ជីប្រជុំក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា ស្ដីពីនីតិវិធី និងយន្តការនៃការផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិ

### ២.៣.៣. ផ្នែកតំហែទាំ (Maintenance)

- ត្រួតពិនិត្យបន្ទប់ Server ជារៀងរាល់ចុងសប្តាហ៍
- បង្កើត policy ថ្មីនៅលើ Symantec Server កំណត់ Live Update ជារៀងរាល់បួនម៉ោងម្តង និងធ្វើការ Scan ជារៀងរាល់ម៉ោង ៨យប់ សម្រាប់ម៉ាស៊ីន Server សម្រាប់ Client វិញ កំណត់ឱ្យ Live Update ជារៀងរាល់ ៤ម៉ោងម្តង និងធ្វើការ Scan ជារៀងរាល់ម៉ោង១២ ថ្ងៃត្រង់ (សម្រាប់ការិយាល័យបញ្ជិកា Scan នៅម៉ោង ១២: ៣០ ថ្ងៃត្រង់) និងកំណត់ឱ្យផ្ញើសារដោយស្វ័យប្រវត្តមកអ៊ីម៉ែល ប.ស.ស Gmail និង Yahoo
- សហការរវាងផ្នែកតំហែទាំ និងផ្នែកណែតវើកដោះស្រាយបញ្ហា QMS មិនបោះលេខលើអេក្រង់ទូរទស្សន៍
- ជួសជុលកុំព្យូទ័រ និងផ្លាស់ប្តូរ UPS ដែលខូច តភ្ជាប់បណ្តាញណែតវើកថ្មី និងដោះស្រាយបញ្ហា Error កម្មវិធី ប.ស.ស
- ធ្វើការ Scan Virus គ្រប់កុំព្យូទ័រនៅទីស្នាក់ការកណ្តាល ប.ស.ស
- សម្របសម្រួលដល់ភ្នាក់ងារមន្ទីរពេទ្យ ប.ស.ស ដែលមានបញ្ហាកម្មវិធី HSPIS និងប្រព័ន្ធណែតវើកផ្សេងៗទៀត
- ត្រួតពិនិត្យមើល Symantec Server ថាមានបញ្ហា Clients Virus attack, Live Update, Scan ជាដើម
- ដោះស្រាយបញ្ហា Error ម៉ាស៊ីនព្រីនធ័រ នៅគ្រប់ការិយាល័យទីស្នាក់ការកណ្តាល ប.ស.ស
- ធ្វើការ Call Remote ដើម្បីដោះស្រាយបញ្ហាកម្មវិធី ប.ស.ស និងបញ្ហាផ្សេងៗនៅ
- ធ្វើការសម្របសម្រួល និងដោះស្រាយបញ្ហាដែលកើតមានឡើងនៅគ្រប់ការិយាល័យទីស្នាក់ការកណ្តាល សាខាខេត្ត-ខណ្ឌ នៅតាមន្ទីរពេទ្យដៃគូ ប.ស.ស

## ២.៤. ការងារសវនកម្មផ្ទៃក្នុង

ក្នុងន័យលើកកម្ពស់ប្រសិទ្ធិភាពរបស់គ្រឹះស្ថាន សវនកម្មផ្ទៃក្នុងបានទទួលអនុវត្តចង្កោមសកម្មភាពទី០៥ "ការអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង" មានសកម្មភាពចំនួន ០៣គឺ៖

- សកម្មភាពទី១ ៖ ពង្រឹង និងពង្រីកអភិបាលកិច្ចសវនដ្ឋានផ្ទៃក្នុង
- សកម្មភាពទី២ ៖ គ្រប់គ្រងធនធានមនុស្សរបស់សវនកម្មផ្ទៃក្នុង
- សកម្មភាពទី៣ ៖ ពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង។

## ២.៥. គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទ ឬ បណ្តឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ជាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក ប.ស.ស និយោជក និង ប.ស.ស ដែលគណៈកម្មការនេះមានការចូលរួមត្រីភាគីរួមមានតំណាង ប.ស.ស តំណាងនិយោជក និងកម្មករនិយោជិត។

### ៣. ការងារប្រជុំផ្សព្វផ្សាយអប់រំ និងបង្ការ

ការងារផ្សព្វផ្សាយជាការងារមួយដ៏សំខាន់ ដែល ប.ស.ស បានយកចិត្តទុកដាក់ខ្ពស់ដោយក្នុងនោះបានរៀបចំនូវផែនការផ្សព្វផ្សាយសាធារណៈជាច្រើន ដើម្បីផ្សព្វផ្សាយពីលទ្ធផលសម្រេចបាន, ការងារបង្ការគ្រោះថ្នាក់ការងារ, ការអនុវត្តគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ក៏ដូចជាការពង្រឹងការអនុវត្តបន្ថែមជាមួយផ្នែកពាក់ព័ន្ធរួមមាននិយោជក, តំណាងកម្មករនិយោជិត, អង្គការសហជីព, អង្គភាពផ្តល់សេវាសុខាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ដើម្បីឱ្យទទួលបានព័ត៌មានថ្មីៗពីការអនុវត្តគោលនយោបាយសន្តិសុខសង្គម និងឱ្យមានការចូលរួមផ្សព្វផ្សាយ និងទប់ស្កាត់ហានិភ័យការងារទាំងអស់គ្នា។ ជាការគួរឱ្យកត់សំគាល់នៅឆ្នាំ២០១៧ ការងារផ្សព្វផ្សាយមួយចំនួនត្រូវបានអនុវត្តដូចខាងក្រោម៖

- ប្រជុំផ្សព្វផ្សាយលទ្ធផលការងារសម្រេចបាន របស់ក្រុមការងារ ទ.ស.ប.ក និងក្រុមការងារ ស.ផ.ក
- ប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម និងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារ
- ប្រជុំផ្សព្វផ្សាយស្តីពីការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព
- ប្រជុំផ្សព្វផ្សាយស្តីពីលក្ខខណ្ឌអនាម័យ, សុវត្ថិភាពការងារ, លក្ខខណ្ឌការងារ, អត្ថប្រយោជន៍របបសន្តិសុខសង្គម, វិធានការទប់ស្កាត់ករណីសន្លប់ និងមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត
- ប្រជុំផ្សព្វផ្សាយស្តីពី ការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើមធ្យោបាយដឹកជញ្ជូនដល់អ្នកបើកបរដឹកកម្មករ និងកម្មករនិយោជិត, វគ្គបណ្តុះបណ្តាល និងប្រឡងយកបណ្ណបើកបរ
- ប្រជុំផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលគ្រូបង្គោលអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, គ្រូបង្គោលភ្នាក់ងារសង្គ្រោះបឋម
- ផ្សព្វផ្សាយស្ពតរូបភាពតាមស្ថានីយទូរទស្សន៍ និងស្ពតសំលេងតាមវិទ្យុ
- ព្រឹត្តិបត្រ, ប្រតិទិន, ខិត្តប័ណ្ណ, សៀវភៅផ្សព្វផ្សាយ និងឯកសារចុះបញ្ជិកា ត្រូវបានចែកជូនដល់អ្នកចូលរួមក្នុងកម្មវិធីនីមួយៗ។

ក្រៅពីការងារផ្សព្វផ្សាយខាងលើ ប.ស.ស ក៏មានគេហទំព័រ (www.nssf.gov.kh) ដែលផ្ទុកនូវរាល់ព័ត៌មាន និងឯកសារគតិយុត្តសំខាន់ៗទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងមានបណ្តាញទំនាក់ទំនងសង្គម (Page Facebook www.facebook.com/nssfpage), ប្រព័ន្ធទូរស័ព្ទ និងទំនាក់ទំនងបន្ទាន់ Hot Line ១២៨៦ ដែលបានផ្សព្វផ្សាយនូវព័ត៌មានទាន់ហេតុការណ៍នានា ទាក់ទងនឹងការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គម និងអាចផ្តល់ព័ត៌មានផ្ទាល់ជាមួយនឹងសមាជិកភ្លាមៗ។ មួយវិញទៀត ប.ស.ស ក៏បានធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតជាច្រើនផងដែរ និងបានចាត់បញ្ជូនមន្ត្រីឱ្យចុះធ្វើការផ្សព្វផ្សាយ ពន្យល់ណែនាំដល់បណ្តាសហគ្រាសគ្រឹះស្ថាន ផ្ទាល់ជាពិសេស ការអនុវត្តគោលនយោបាយផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ពីនីតិវិធី និងបែបបទនៃការចុះបញ្ជិកា, ការបង់ភាគទាន និងទាមទារ/ផ្តល់តាវកាលិក (អត្ថប្រយោជន៍) ដែលកម្មករនិយោជិតត្រូវទទួលបាន។

## ៣.១. ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយរបបសន្តិសុខសង្គម

ការពង្រឹងការផ្សព្វផ្សាយគោលនយោបាយរបបសន្តិសុខសង្គម បានធ្វើការផ្សព្វផ្សាយស្តីពីគោលនយោបាយនៃការពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត មកដល់ដំណាច់ឆ្នាំ ២០១៧ នេះ បានធ្វើការប្រជុំផ្សព្វផ្សាយជូនដល់តំណាងសហគ្រាស គ្រឹះស្ថាន ជនរងគ្រោះដែលជាសមាជិក ប.ស.ស តំណាងអង្គភាព មន្ទីរ អាជ្ញាធរមានសមត្ថកិច្ច មូលដ្ឋានផ្តល់សេវាសុខាភិបាល (ចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស) ព្រមទាំងជនរងគ្រោះទាំងអស់ ដែលកំពុងទទួលបានតាវកាលិកហានិភ័យការងារពី ប.ស.ស មកចូលរួមប្រជុំ។

**តារាងទី ១៦ ការងារផ្សព្វផ្សាយ គោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម**

| បរិយាយ | ស្ថានភាពផ្សព្វផ្សាយ | | | អ្នកចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|---|
| | លើក | និយោជក/សហជីព/ជនរងគ្រោះ/អាជ្ញាធរ | រាជធានី-ខេត្ត | សរុប | ស្រី |
| ឆ្នាំ2017 | 428 | 48,683 | 25 | 57,329 | 45,807 |
| ឆ្នាំ2016 | 74 | 12,868 | 25 | 12,868 | 5,274 |
| ឆ្នាំ2015 | 46 | 4,841 | 19 | 6,188 | 2,475 |
| ឆ្នាំ2014 | 23 | 2,907 | 8 | 1,682 | 673 |
| សរុប 2014-2017 | 571 | 69,299 | 25 | 78,067 | 54,229 |

**តារាងទី ១៦.១ ផ្សព្វផ្សាយ ផ្នែកថែទាំសុខភាព**

| បរិយាយ | ស្ថានភាពផ្សព្វផ្សាយ | | | អ្នកចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|---|
| | លើក | និយោជក/សហជីព/ជនរងគ្រោះ/អាជ្ញាធរ | រាជធានី-ខេត្ត | សរុប | ស្រី |
| ឆ្នាំ2017 | 250 | 28,258 | 13 | 33,276 | 27,118 |
| ឆ្នាំ2016 | 35 | 5,704 | 5 | 5,704 | 2,408 |
| បម្រែបម្រួល (± %) | 614.29% | 395.41% | 160.00% | 483.38% | 1026.16% |

## ៣.២. ក្រុមការងារ ប.ស.ស សហការជាមួយក្រុមការងារផ្សព្វផ្សាយពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ

**តារាងទី ១៧៖ ក្រុមការងារ ប.ស.ស សហការជាមួយក្រុមការងារផ្សព្វផ្សាយ ពង្រឹងគោលនយោបាយ អភិវឌ្ឍន៍វិស័យការងារ**

| បរិយាយ | សហគ្រាសបានទទួលការផ្សព្វផ្សាយអប់រំ | | កម្មករនិយោជិតចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|
| | រោងចក្រ | លើក | សរុប | ស្រី |
| ឆ្នាំ2017 | 727 | 727 | 142,187 | 123,072 |
| ឆ្នាំ2016 | 91 | 91 | 8,728 | 7,371 |
| បម្រែបម្រួល (± %) | 698.90% | 698.90% | 1529.09% | 1569.68% |

ប្រភព៖ បេឡាជាតិរបបសន្តិសុខសង្គម

## ៣.៣. ការងារប្រជុំផ្សព្វផ្សាយបង្ការហានិភ័យការងារ

### ៣.៣.១. ក្រុមការងារ ទ.ស.ប.ក

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) មានតួនាទីសិក្សាស្រាវជ្រាវ រកមូលហេតុករណីសន្លប់របស់កម្មករនិយោជិតចាត់វិធានការសង្គ្រោះបន្ទាន់ និងសម្របសម្រួលជាមួយមន្ទីរពេទ្យ ជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីឱ្យជនរងគ្រោះទទួលបានការសង្គ្រោះបន្ទាន់ និងចូលរួមរៀបចំការផ្សព្វផ្សាយពីកម្មវិធីបង្ការគ្រោះថ្នាក់ការងារ។ ក្រុមការងារ ទ.ស.ប.ក បាននិងកំពុងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ

អប់រំដូចភ្លៀងរលឹម ដើម្បីឱ្យនិយោជក តំណាងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ទទួលបានការអប់រំស្តីពីលក្ខខណ្ឌការងារ, លក្ខខណ្ឌអនាម័យ និងសុវត្ថិភាពការងារ, ការទប់ស្កាត់ករណីកម្មករ និយោជិតសន្លប់ បង្ការគ្រោះថ្នាក់ចរាចរណ៍ដោយមធ្យោបាយធ្វើដំណើរកម្មករនិយោជិត និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ក្នុងន័យទប់ស្កាត់ និងបង្ការគ្រោះថ្នាក់ការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ឱ្យស្ថិតនៅកម្រិតទាបបំផុត។

ក្នុងបាតុភាពករណីកម្មករនិយោជិតសន្លប់ ក្រុមការងារ ទ.ស.ប.ក ក៏បានចុះជួយសម្របសម្រួលចាត់វិធានការកែលំអ និងជួយសង្គ្រោះ។

### ស្ថានភាពបាតុភាពករណីសន្លប់ និងការផ្សព្វផ្សាយអប់រំកម្មករនិយោជិតឆ្នាំ២០០៨ និងឆ្នាំ២០១៧

- ***ស្ថានភាពបាតុភាពករណីសន្លប់***

*ក្រាហ្វិកទី៨. ចំនួនរោងចក្រ និងកម្មករនិយោជិតសន្លប់*







មូលហេតុសន្លប់បណ្តាលមកពី៖
- សាយភាយថ្នាំគីមីដែលប្រជាជនបាញ់ដាក់ស្រែ
- ផ្សិតទឹកដែលប្រើប្រាស់មានធូលីដី
- បរិស្ថាននៅជុំវិញអគារផលិតកម្មមិនសម្អាតត្រឹមត្រូវ
- បរិយាកាសណ៍កម្តៅក្នុងអាគារផលិតកម្មក្តៅ និងហប់
- តានតឹងអារម្មណ៍ និង
- ស្លន់ស្លោ ភ័យតៗគ្នា

- ***ការផ្សព្វផ្សាយអប់រំ***

**តារាងទី ១៨ ការប្រជុំផ្សព្វផ្សាយ អប់រំទប់ស្កាត់ករណីកម្មករសន្លប់**

| បរិយាយ | សហគ្រាស | | កម្មករនិយោជិត | |
|---|---|---|---|---|
| | រោងចក្រ | លើក | សរុប | ស្រី |
| ឆ្នាំ2017 | 88 | 88 | 7,296 | 5,129 |
| ឆ្នាំ2016 | 77 | 77 | 13,042 | 11,738 |
| ឆ្នាំ2015 | 90 | 90 | 13,450 | 12,105 |
| ឆ្នាំ2014 | 27 | 19 | 3,100 | 2,790 |
| ឆ្នាំ2013 | 71 | 32 | 10,917 | 9,825 |
| ឆ្នាំ2012 | 15 | 105 | 28,000 | 25,200 |
| សរុប 2012-2017 | 368 | 411 | 75,805 | 66,787 |

## ៣.៣.២.ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត

បច្ចុប្បន្នគ្រោះថ្នាក់ចរាចរណ៍ ជាបន្ទុកដ៏ធំដល់រាជរដ្ឋាភិបាល ដោយសារជនរងគ្រោះបានបាត់បង់ជីវិត របួស ពិការ ខូចខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជនយ៉ាងច្រើន ជាពិសេសកម្មករ-កម្មការិនី ដែលទទួលរងគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងធ្វើដំណើរទៅ និងត្រឡប់មកពីបំពេញការងារដោយមធ្យោបាយនានា។ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយ ក៏ដូចជាទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ នេះ បេឡាជាតិរបបសន្តិសុខសង្គម តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតហៅកាត់ថា (ស.ផ.ក) ដោយសេចក្តីសម្រេចលេខ០០២/១៣ ក.ប/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ដែលមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ, តំណាងភាគីនិយោជក, កម្មករនិយោជិត និងអង្គការជនពិការអន្តរជាតិ(HI)។ ក្រុមការងារនេះមានភារកិច្ចកសាងផែនការសកម្មភាព, សិក្សាស្រាវជ្រាវប្រមូលទិន្នន័យវិភាគ, ស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត, ផ្សព្វផ្សាយអប់រំណែនាំពីច្បាប់ និងសុវត្ថិភាពចរាចរណ៍ និងសហការជាមួយអាជ្ញាធរ ដែនដី សមត្ថកិច្ចពាក់ព័ន្ធក្នុងការចាត់វិធានការបង្ការ និងទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ ព្រមទាំងអនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្រាប់ឆ្នាំ២០១៧ នេះ ក្រុមការងារបានរៀបចំផែនការការងារ និងសម្ភារឧបទ្ទេសសម្រាប់ផ្សព្វផ្សាយអប់រំដល់អ្នកបើកបរដឹកកម្មករនិយោជិត កម្មករ/កម្មការិនី ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក, បច្ចេកទេសត្រួតពិនិត្យយានយន្ត, វិជ្ជាសង្គ្រោះបឋម, ពាក់មួកសុវត្ថិភាព និងវិធីការពារគ្រោះថ្នាក់ផ្សេងៗជាពិសេសចំណុចដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ជាញឹកញាប់ និងការងារមួយចំនួនទៀត បានគួរឱ្យកត់សំគាល់ ដូចបង្ហាញលទ្ធផលខាងក្រោម៖

**តារាងទី ១៩៖ ស្ថានភាពគ្រោះ ថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត**

| គ្រោះថ្នាក់ចរាចរណ៍របស់កម្មករ | ករណី | ស្ថានភាពជនរងគ្រោះ(នាក់) | | | | | យានយន្តទូទៅ(%) | | | យានយន្តបង្កហេតុ(%) | | តាមវិស័យ(%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្លាប់ | ធ្ងន់ | ស្រាល | សរុប | ស្រី | ម៉ូតូ | រថយន្ត | ផ្សេងៗ | បង្កឡើងដោយយានយន្តដឹកកម្មករ | បង្កឡើងដោយយានយន្តដទៃ | រោងចក្រ | ធនាគារ/មីក្រូហិរ- | ផ្សេងៗ |
| ឆ្នាំ2017 | 1,771 | 36 | 320 | 1,970 | 2,326 | 2,326 | 87.62% | 3.96% | 8.42% | 45.10% | 54.52% | 50.52% | 18.71% | 30.77% |
| ឆ្នាំ2016 | 7,592 | 118 | 1,293 | 7,898 | 9,309 | 5,839 | 73.00% | 15.00% | 13.00% | 39.00% | 61.00% | 66.00% | 7.00% | 27.00% |
| បម្រែបម្រួល (± %) | -76.67% | -69.49% | -75.25% | -75.06% | -75.01% | -60.16% | 20.03% | -73.60% | -35.23% | 15.64% | -10.62% | -23.45% | 167.29% | 13.96% |

ប្រភព៖ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់ គាំពារកម្មករនិយោជិត (ស.ផ.ក) ឆ្នាំ2017

- ***ការងារផ្សព្វផ្សាយដល់កម្មករនិយោជិត***

**តារាងទី ២០ ផ្សព្វផ្សាយ ច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក និងវិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍**

| បរិយាយ | សហគ្រាស | | កម្មករនិយោជិត | | | |
|---|---|---|---|---|---|---|
| | រោងចក្រ | លើក | កម្មករនិយោជិត | អ្នកបើកបរ | សរុបរួម | ស្រី |
| ឆ្នាំ2017 | 671 | 682 | 60,677 | 30,241 | 90,918 | 55,093 |
| ឆ្នាំ2016 | 154 | 137 | 24,922 | 1,488 | 26,410 | 15,794 |
| ឆ្នាំ2015 | 307 | 103 | 17,776 | 3,591 | 21,367 | 12,820 |
| ឆ្នាំ2014 | 123 | 22 | 2,675 | 1,600 | 4,275 | 2,565 |
| ឆ្នាំ2013 | 172 | 24 | 2,880 | 1,867 | 4,747 | 2,848 |
| សរុប | 1,427 | 968 | 108,930 | 38,787 | 147,717 | 89,120 |

ប្រភព៖ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) ឆ្នាំ2013-ឆ្នាំ2017

## III. បញ្ហាប្រឈមក្នុងការអភិវឌ្ឍរបបសន្តិសុខសង្គម

### ក.បញ្ហាប្រឈមការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

### ១. បញ្ហាប្រឈមលើការពង្រឹង និងពង្រីកការអនុវត្តផ្នែកហានិភ័យការងារ

រហូតមកដល់ឆ្នាំ២០១៧ នេះ បេឡាជាតិរបបសន្តិសុខសង្គម នៅជួបបញ្ហាប្រឈមមួយចំនួនដូចតទៅ៖

***១.១. និយោជកសហគ្រាស គ្រឹះស្ថាន មួយចំនួនតូច៖***

- មិនទាន់ស្គាល់ពី ប.ស.ស ច្បាស់ពាក់ព័ន្ធនឹងនីតិវិធីចុះបញ្ជិកា បង់ភាគទាន និងផ្តល់ទិន្នន័យកម្មករនិយោជិតមិនច្បាស់តាមខែនីមួយៗ
- ពិបាកជួបម្ចាស់សហគ្រាស (ភោជនីយដ្ឋាន, ក្លឹមកំសាន្ត, ខារ៉ាអូខេ,...)
- ពន្យាពេលក្នុងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត
- បិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូររដ្ឋបាលថ្មី ប្តូរម្ចាស់ ប្តូរយីហោថ្មី ដោយមិនបានជូនដំណឹងមក ប.ស.ស
- ប្រភេទសិប្បកម្មមិនរៀបរយ គ្មានឯកសារគតិយុត្តត្រឹមត្រូវ
- ផ្តល់របាយការណ៍ហានិភ័យការងារមិនត្រឹមត្រូវ យឺតយ៉ាវ រក្សាទុកឯកសារទាមទារតាវកា-លិកយូរ ឬចាំសរុបរួមទើបផ្ញើមក ប.ស.ស
- មិនទាន់បង់ភាគទានហានិភ័យការងារ

***១.២. កម្មករនិយោជិតមួយចំនួនតូច៖***

- មិនទាន់យល់ច្បាស់ពី ប.ស.ស មិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណច្បាស់ និងទាមទារតាវកាលិកមិនមែនគ្រោះថ្នាក់ការងារ
- មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍
- ទៅទទួលការព្យាបាលនៅមន្ទីរពេទ្យ ដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស និងប្រើប្រាស់សេវាមិនចំគោលដៅ

***១.៣.សេវាមូលដ្ឋានសុខាភិបាលមួយចំនួន៖***

គុណភាពនៃការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ របស់មន្ទីរពេទ្យមូលដ្ឋានមួយចំនួននៅមានកម្រិត។

### ២. បញ្ហាប្រឈមលើការពង្រឹង និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព

ការអនុវត្តផ្នែកថែទាំសុខភាព បេឡាជាតិរបបសន្តិសុខសង្គម ជួបបញ្ហាប្រឈមមួយចំនួនដូចតទៅ៖

***២.១. និយោជកសហគ្រាស គ្រឹះស្ថានមួយចំនួនតូច៖***

- ការកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ
  - ✓ ពន្យាពេលក្នុងការចុះ
  - ✓ ខ្លាចប៉ះពាល់សង្វាក់ផលិតកម្ម ដោយបញ្ជូនកម្មករនិយោជិតមកតិច

- មិនបានរាយការណ៍ពីចំនួនបុគ្គលិកចូលថ្មី និងលាឈប់ពីការងារ និងមួយចំនួនទៀតបានរាយការណ៍ដែរ តែមិនច្បាស់លាស់
- មិនទាន់បង់ភាគទានផ្នែកថែទាំសុខភាពមាន។

***២.២.កម្មករនិយោជិតមួយចំនួនតូច៖***

- ការកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ
  - ✓ ខ្ជិលឯកសារគេប្រើ មិនហ៊ានប្រាប់ខ្លាចគេបញ្ឈប់ពីការងារ
  - ✓ មិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ផ្នែកថែទាំសុខភាព
  - ✓ ខ្លាចបាត់បង់អតីតភាពការងារពេលប្តូរឈ្មោះត្រឹមត្រូវវិញ
- ព្យាយាមលាក់បាំងមិនព្រមបង្ហាញកាតដោយយល់ថា គ្រូពេទ្យផ្តល់សេវាល្អទាល់តែបង់ប្រាក់ភ្លាមៗ។

***២.៣.សេវាមូលដ្ឋានសុខាភិបាលមួយចំនួនតូច៖***

គ្រូពេទ្យមួយចំនួនតូចមិនទាន់យល់ច្បាស់អំពីលំហូរ នៃការផ្តល់សេវាជូនសមាជិកដោយរលូន (បញ្ជូនអ្នកជំងឺពីមួយទៅមួយ) និងផ្តល់ឱសថសារវ័ន្តដល់សមាជិកមិនគ្រប់គ្រាន់។

**៣. បញ្ហាប្រឈមលើការជំរុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន**

៣.១. កង្វះធនធានមនុស្ស

៣.២. ខ្វះជំនាញការសម្រាប់ការគណនាគណិតវិទ្យាលើការបង់ភាគទាន និងការផ្តល់តាវកាលិក

៣.៣. ខ្វះទិន្នន័យដែលជាមូលដ្ឋានសម្រាប់ការសិក្សា និងវិភាគ

៣.៤. មិនទាន់រៀបចំសិក្សាសមិទ្ធិលទ្ធភាពនៃការអនុវត្ត

**ខ. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

១.ការចុះបញ្ជីមន្ត្រីសាធារណៈមិនទាន់ឆ្លើយតបទៅនិងមន្ត្រីរាជការសរុប

២.មន្ត្រីសាធារណៈមិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ដែលខ្លួនត្រូវទទួលបាន

៣.ការផ្សព្វផ្សាយនៅមិនទាន់ទូលំទូលាយ

**គ. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន**

១. ពិបាកក្នុងការអញ្ជើញនិយោជកមកចុះបញ្ជី សហគ្រាស និងកម្មករនិយោជិត

២. និយោជកមិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ដែលកម្មករនិយោជិតនឹងទទួលបាន

៣. ការជូនដំណឹងមក ប.ស.ស មានការយឺតយ៉ាវ

៤. កម្មករនិយោជិតជាស្ត្រីមិនមានអត្តសញ្ញាណប័ណ្ណ ឬអត្តសញ្ញាណប័ណ្ណមិនច្បាស់លាស់

៥. កម្មករនិយោជិតមិនទាន់យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធធនាគារ

៦. ទូរស័ព្ទមិនមែនជាប្រភេទស្មាតហ្វូន

**ឃ. ការងារគាំទ្រការអនុវត្ត**

១. បញ្ហាធនធានមនុស្សនៅមានកម្រិត

២. ការអនុវត្តរបបសន្តិសុខសង្គមមិនទាន់ទូលំទូលាយ

៣. ពិបាករកជំនាញវេជ្ជបណ្ឌិត

៤. បញ្ហាសន្លប់នៅតែបន្តកើនឡើង

៥. គ្រោះថ្នាក់ចរាចរណ៍បង្កឡើងដោយអ្នកបើកបរដឹកកម្មករមានការកើនឡើង

៦. និយោជក និងកម្មករនិយោជិតមួយចំនួនមិនទាន់ស្គាល់ ប.ស.ស

**IV.ការដោះស្រាយ និងទិសដៅអនុវត្តបន្ត**

ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឲ្យមានប្រសិទ្ធភាព ទាន់ពេលវេលា និងដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានា បេឡាជាតិរបបសន្តិសុខសង្គម មានទិសដៅសំខាន់ៗមួយចំនួនសម្រាប់អនុវត្តបន្ត ដូចខាងក្រោម៖

**ក.ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ**

**១. ការពង្រឹង និងពង្រីកការអនុវត្តផ្នែកហានិភ័យការងារ**

***១.១. និយោជកសហគ្រាស គ្រឹះស្ថាន គ្រូវសហការៈ***

- បន្តផ្សព្វផ្សាយពន្យល់ណែនាំពីយន្តការអនុវត្តជាធរមាន
- បន្តព្យាយាមសម្របសម្រួលណាត់ជួបនៅពេលរសៀល និងពន្យល់ឱ្យអស់លទ្ធភាពមុននឹងចាត់វិធានការ
- ចុះសម្របសម្រួល និងពន្យល់ផ្ទាល់ ដើម្បីកំណត់ពីស្ថានភាពសហគ្រាសដំណើរការ ឬមិនដំណើរការ
- ព្យាយាមទំនាក់ទំនងផ្ទាល់ ដើម្បីជួយបង្រៀនឱ្យចេះរៀបចំឯកសារបង់ភាគទាន និងឯកសារទាមទារតាវកាលិក
- ចុះទៅទារផ្ទាល់តាមរយៈការដាក់លិខិតកំហិត។

***១.២.កម្មករនិយោជិតត្រូវ៖***

- ចុះសម្របសម្រួល និងពន្យល់ផ្ទាល់ពីគោលការណ៍ជាធរមាន
- ជំរុញឱ្យចុះសំបុត្រអាពាហ៍ពិពាហ៍
- ណែនាំឱ្យទៅយកសេវាជាមួយមូលដ្ឋានសុខាភិបាល ដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស វិញ។

***១.៣. សេវាមូលដ្ឋានសុខាភិបាល***

- សម្របសម្រួលជាមួយនឹងមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងដោយផ្តល់សេវាបានកាន់តែល្អប្រសើរ និងប្រជុំដោះស្រាយបញ្ហាប្រឈមនានា
- បន្តចុះកិច្ចព្រមព្រៀង និងដាក់ភ្នាក់ងារ ប.ស.ស នៅតាមមូលដ្ឋានសុខាភិបាលនោះ។

## ២. ការពង្រឹង និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព

### ២.១. និយោជកសហគ្រាស គ្រឹះស្ថាន ត្រូវសហការ៖

- ចុះពន្យល់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណ សមាជិក និងការផ្តល់សេវា
- ណែនាំប្រាប់ពីរបៀបរៀបចំរបាយការណ៍ចំនួនបុគ្គលិកឱ្យបានត្រឹមត្រូវ។

### ២.២.កម្មករនិយោជិតត្រូវ៖

- ចុះពន្យល់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណសមាជិកជាថ្មី (ផ្សព្វផ្សាយសេចក្តីជូនដំណឹង លេខ ១២៧ ក.ប/ស.ជ.ណ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុង ប.ស.ស)
- ចុះពន្យល់ និងផ្សព្វផ្សាយពីតាវកាលិកថៃទាំសុខភាព និងសម្របសម្រួលសមាជិកឱ្យប្រើប្រាស់សេវាតាមរយៈភ្នាក់ងារ ប.ស.ស នៅតាមមន្ទីរពេទ្យ។

### ២.៣. សេវាមូលដ្ឋានសុខាភិបាល

- ប្រជុំពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយក្នុងការផ្តល់ឱសថ និងសេវាឱ្យរលូន
- សម្របសម្រួល និងស្នើសុំគ្រូពេទ្យមិនឱ្យផ្សព្វផ្សាយលក់ផលិតផលដល់សមាជិក
- បន្តចុះកំណត់កម្រិតផ្តល់សេវា និងកិច្ចព្រមព្រៀងទូទាំង២៥រាជធានី-ខេត្ត
- ចុះពន្យល់ពីវិធីសាស្ត្រទូទាត់ថ្លៃសេវា
- ចុះពន្យល់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណសមាជិកនៅ តាមមូលដ្ឋានសុខាភិបាលតាមរយៈប្រព័ន្ធ SMS and H-SPIS ។

## ៣. ការជំរុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន

៣.១. ជ្រើសរើសបុគ្គលិក និងបណ្តុះបណ្តាលធនធានមនុស្ស

៣.២. ស្នើសុំសហការជាមួយនឹងដៃគូអភិវឌ្ឍក្នុងការរៀបចំយន្តការអនុវត្ត និងបណ្តុះបណ្តាលធនធានមនុស្ស

៣.៣. ស្នើសុំពីដៃគូអភិវឌ្ឍឱ្យមានអ្នកជំនាញការគណិតវិទ្យាក្នុងការស្រាវជ្រាវ និងប្រមូលទិន្នន័យសម្រាប់ ធ្វើការវិភាគលើការបង់ភាគទាន និងសេវាត្រូវផ្តល់

៣.៤. រៀបចំសិក្សាសមិទ្ធលទ្ធភាពដាក់ឱ្យអនុវត្ត, ស្នើសុំគោលការណ៍ដាក់ឱ្យអនុវត្ត និងរៀបចំលិខិតបទដ្ឋានគតិយុត្ត។

## ខ. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

១. ជម្រុញការចុះបញ្ជីមន្ត្រីសាធារណៈដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាព សាមី

២. ត្រូវបង្កើនការផ្សព្វផ្សាយគ្រប់វិធីសាស្ត្រតាមរយៈ

- ការប្រជុំផ្សព្វផ្សាយដោយផ្ទាល់
- ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ហ្វេសបុក គេហទំព័រ និង
- តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។

**គ. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន**

១. ជម្រុញការចុះអញ្ជើញនិយោជកឱ្យមកចុះបញ្ជីដើម្បីឱ្យកម្មករទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គម

២. ជម្រុញឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ

៣. ជម្រុញការផ្សព្វផ្សាយព័ត៌មានដល់និយោជក ឬអ្នកតំណាង និងកម្មករនិយោជិត

៤. ព្យាយាមពន្យល់ដល់កម្មករនិយោជិតដោយផ្ទាល់ នៅពេលកម្មករនិយោជិតមកបំពេញទម្រង់ឯកសារ ស្នើសុំប្រាក់ឧបត្ថម្ភនៅទីស្នាក់ការ ប.ស.ស

៥. ណែនាំឱ្យកម្មករនិយោជិតយល់ពីលេខទូរស័ព្ទបន្ទាន់ ១២៨៦

៦. ពន្យល់ និងជម្រុញឱ្យមានអត្តសញ្ញាណប័ណ្ណច្បាស់លាស់។

**ឃ. ការខារគាំទ្រការអនុវត្ត**

១. ករណីធនធានមនុស្សនៅមានកម្រិត

- រៀបចំវគ្គបណ្តុះបណ្តាល
- ស្នើសុំដៃគូអភិវឌ្ឍន៍នូវវគ្គបណ្តុះបណ្តាលទាំងខាងក្នុង និងក្រៅប្រទេស
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់រយៈពេលវែង

២. រៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

៣. រៀបចំលក្ខន្តិកៈដោយឡែកសម្រាប់លើកទឹកចិត្តបន្ថែមលើជំនាញវេជ្ជបណ្ឌិត

៤. បង្កើនការផ្សព្វផ្សាយពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ វិធានការទប់ស្កាត់ករណីសន្លប់

៥. ករណីគ្រោះថ្នាក់ចរាចរណ៍

- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធជម្រុញឱ្យអ្នកបើកបរត្រូវ៖
  - ✓ ផ្លាស់ប្តូររថយន្តដឹកទំនិញ/រថយន្តទ្រុង ដែលកែច្នៃខុសច្បាប់ មកប្រើប្រាស់រថយន្តដឹកជញ្ជូនអ្នកដំណើរដែលមានកៅអីត្រឹមត្រូវ
  - ✓ ចុះបង្រៀនអំពីច្បាប់ស្តីពីចរាចរណ៍ដល់អ្នកបើកបររថយន្តដឹកកម្មករ

៦. បង្កើនការផ្សព្វផ្សាយពីគោលនយោបាយរបបសន្តិសុខសង្គមដល់និយោជក និងកម្មករនិយោជិតឱ្យបានកាន់តែទូលំទូលាយ។

## សេចក្តីសន្និដ្ឋាន

ក្នុងការអនុវត្តការងាររយៈពេល ១០ឆ្នាំ នៃការអនុវត្តអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងអនុក្រឹត្យស្តីពីការបង្កើត ប.ស.ស សម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈដោយផ្អែកលើ យុទ្ធសាស្ត្រចតុកោណ, យុទ្ធសាស្ត្រអភិវឌ្ឍជាតិ, យុទ្ធ-សាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ២០១៤-២០១៨។

ទន្ទឹមនឹងលទ្ធផលការងារខាងលើ ប.ស.ស បានសង្កេតឃើញនៅមានបញ្ហាប្រឈមមួយចំនួនទៀត ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់និយោជក និងកម្មករនិយោជិតមួយចំនួនតូច គុណភាពនៃការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រត្រូវបានកែលម្អជាបន្តបន្ទាប់ និងបញ្ហារបស់ ប.ស.ស មួយចំនួនផងដែរ។ ទាក់ទងនឹងបញ្ហាប្រឈមនេះ ប.ស.ស ក៏បានកត់សំគាល់ឃើញថា ចំនួនគ្រោះថ្នាក់ការងារនៅតែមានការកើនឡើងស្របនឹងការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលបានចុះបញ្ជិកានៅ ប.ស.ស ជាពិសេសករណីរបួសធ្ងន់ ទោះបីជាករណីគ្រោះថ្នាក់នៅពេលធ្វើដំណើរមានការកើនឡើងបន្តិចក៏ដោយ ក៏ករណីនេះនៅតែមានចំនួនគួរឱ្យព្រួយបារម្ភផងដែរ។ ដូចនេះ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមខាងលើវាទាមទារឱ្យមានការបន្តជួយជ្រោមជ្រែង គាំទ្រសហការបន្ថែមទៀតពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា នៅក្នុងការអភិវឌ្ឍវិស័យសន្តិសុខសង្គមនៅកម្ពុជាឱ្យមានការរីកចម្រើន និងសូមឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការចាត់វិធានការអប់រំផ្សព្វផ្សាយ ដើម្បីបង្ការ និងទប់ស្កាត់ក្នុងកម្រិតគ្រោះថ្នាក់ការងារឱ្យនៅទាបបំផុត ដែលជាផ្នែកមួយចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។ ម្យ៉ាងវិញទៀត កម្មករនិយោជិតខ្លួនឯងផ្ទាល់ត្រូវមានការយល់ដឹងចំពោះបញ្ហាសុខភាព និងប្រុងប្រយ័ត្នខ្ពស់នៅក្នុងការបំពេញការងារ ជាពិសេសការធ្វើដំណើរទៅមក ដើម្បីជៀសវាងកុំឱ្យមានគ្រោះថ្នាក់ព្រោះវានាំឱ្យខាតបង់ការងារ ពេលវេលា ថវិកា និងជាយថាហេតុបណ្តាលឱ្យបាត់បង់ដល់អាយុជីវិតទៀតផង។

ផ្អែកលើសមិទ្ធិផលសម្រេចកន្លងមក ដោយសារថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស ទាំងអស់បានយកចិត្តទុកដាក់បំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងឆន្ទៈទទួលខុសត្រូវខ្ពស់រួមទាំងមានការគាំទ្រសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមអនុវត្តច្បាប់បានល្អប្រសើរពីសំណាក់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។

ថ្ងៃ សុក្រ ១រោច ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ុក-សមវិទ្យា**

# អាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងជាមួយ ប.ស.ស តាមបណ្តាខេត្ត-ខណ្ឌ

| ល.រ | ខេត្ត | អាសយដ្ឋាន | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|---|---|
| ១ | ខេត្តកណ្តាល | ផ្ទះលេខ០១ ផ្លូវលេខ២០២, ភូមិដើមមៀន,<br>សង្កាត់ដើមមៀន, ក្រុងតាខ្មៅ, ខេត្តកណ្តាល | ០៨៥ ៥៦៧ ៧៦៦<br>៩៧៧ ៩៦៣ ០៧៨ | ០២៤ ៦៤០ ១៦៧៦ | samphearak@nssf.gov.kh |
| | | ភូមិក្នុង, ឃុំព្រែកតាមាក់, ស្រុកខ្សាច់កណ្តាល,<br>ខេត្តកណ្តាល | ០៩៦ ៦១៥ ៦១៦៨<br>០១២ ៥៤៨ ៨០៥<br>០៩៨ ៥៤៨ ៨០៥ | ០២៣ ៥១៩ ៨៩៩៩ | nssf_reythearith@nssf.gov.kh |
| ២ | ខេត្តកំពង់ស្ពឺ | សាខាទី១<br>ផ្លូវជាតិលេខ៤ ភូមិចុងបង្គោល ឃុំបែកចាន<br>ស្រុកអង្គស្នួល ខេត្តកណ្តាល<br>សាខាទី២<br>ផ្លូវជាតិលេខ៤ ភូមិចំការដូង សង្កាត់ច្បារមន<br>ក្រុងច្បារមន ខេត្តកំពង់ស្ពឺ | ០១២ ២៨៦ ៨៧៩<br>០១៥ ២១០ ២១០<br>០៦០ ២១២ ២១២ | ០២៤ ៥០៨ ០៧៧៧ | movratha@yahoo.com |
| ៣ | ខេត្តស្វាយរៀង | ផ្លូវជាតិលេខ០១, ភូមិរោងបន្លែ, សង្កាត់ស្វាយរៀង,<br>ក្រុងស្វាយរៀង, ខេត្តស្វាយរៀង | ០៧៧ ៦៦៣ ២១៤ | ០៤៤ ៧១៥ ៨៣១ | pek.samol@nssf.gov.kh |
| ៤ | ខេត្តព្រះសីហនុ | សង្កាត់លេខ០៤, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ | ០១៧ ៩៣៣ ៣៩៦<br>០៧៧ ៦៦៣ ២១៥ | ០៣៤ ៩៣៤ ៦០៦ | tong_samnieng@nssf.gov.kh |
| ៥ | ខេត្តកំពង់ឆ្នាំង | ផ្ទះលេខC៤៩៥, ក្រុមទី១៨, ភូមិម៉ុងបារាំង,<br>សង្កាត់ប្អេរ, ក្រុងកំពង់ឆ្នាំង, ខេត្តកំពង់ឆ្នាំង | ០៧៧ ៦៦៣ ២១៦<br>០១៦ ៨៨៤ ៣៤៨ | ០២៦ ៩៨៨ ៨៩១<br>០២៦ ៧៧៥ ៥៦៦ | nssf_kcn@nssf.gov.kh |
| ៦ | ខេត្តសៀមរាប | បុរីសៀងណាំ, ភូមិខ្នារ, សង្កាត់ជ្រាវ, ក្រុងសៀមរាប,<br>ខេត្តសៀមរាប | ០១២ ៥៣៤ ៣៤៥<br>០៧៧ ៦៦៣ ២១៧ | ០៦៣ ៩៦៥ ៩៣៤ | pang_sokchea@yahoo.com<br>sokchea@nssf.gov.kh |
| ៧ | ខេត្តបន្ទាយមានជ័យ | ភូមិគីឡូម៉ែតលេខ០៤, សង្កាត់ផ្សារកណ្តាល,<br>ក្រុងប៉ោយប៉ែត, ខេត្តបន្ទាយមានជ័យ | ០៧៧ ៦៦៣ ២១៨<br>០៨៩ ៩៨៧ ៨៨៧ | ០៥៤ ៧១១ ៤៤១ | nssf_bmc@nssf.gov.kh |
| | | ភូមិ០៣, សង្កាត់ព្រពន្លា, ក្រុងសិរីសោភ័ណ, ខេត្តបន្ទាយមានជ័យ | | | |
| ៨ | ខេត្តកំពង់ចាម | សាខាទី១<br>ផ្លូវលេខ៦A, ភូមិបាធាយ, ឃុំបាធាយ, ស្រុកបាធាយ,<br>ខេត្តកំពង់ចាម | ០១២ ៥២០ ៧៦៧<br>០៧៧ ៩៩០ ០៤៨ | ០៤២ ៦៥២ ១៩៩៩<br>០៤២ ៩៤៣ ៣៨៨ | say.sothon@nssf.gov.kh |

| ល.រ | ខេត្ត | អាសយដ្ឋាន | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|---|---|
| | | សាខាទី២<br>ភូមិទី៤, សង្កាត់វាលវង់, ក្រុងកំពង់ចាម,<br>ខេត្តកំពង់ចាម | | | |
| ៩ | ខេត្តក្រចេះ | ផ្លូវជាតិលេខ៧, ភូមិអូរឫស្សី, សង្កាត់អូរឫស្សី,<br>ក្រុងក្រចេះ, ខេត្តក្រចេះ | ០៩២ ៨៧៣ ០៥១<br>០៩៧ ២៦២ ៧៥៤៧ | ០៧២ ២១០ ៤២៣ | kratie@nssf.gov.kh<br>soksay.he@nssf.gov.kh |
| ១០ | ខេត្តព្រៃវែង | ផ្ទះលេខ១០៧, ភូមិលេខ០៣, សង្កាត់កំពង់លាវ,<br>ក្រុងព្រៃវែង, ខេត្តព្រៃវែង | ០១២ ៥៤៨ ៨០៥<br>០៩២ ៧០៨ ៨០៣ | | reythearith@yahoo.com<br>rey.thearith@nssf.gov.kh |
| ១១ | ខេត្តតាកែវ | ផ្លូវលេខ០៣, ភូមិចក, សង្កាត់រកាក្នុង, ក្រុងដូនកែវ,<br>ខេត្តតាកែវ | ០១២ ៦៣៦ ៤៣៩ | ០៣២ ២១០ ៦៦៦ | vannak-rk@nssf.gov.kh<br>vannaknssf@gmail.com |
| ១២ | ខេត្តកំពត | ភូមិ០១ឧសភា, ឃុំកំពង់កណ្តាល, ស្រុកកំពុងបាយ,<br>ក្រុងកំពត, ខេត្តកំពត | ០១២ ៦២៣ ៣៣២ | ០៣៣ ៩៣២ ១៣៣ | phokchetra@gmail.com<br>sin.kosal@nssf.gov.kh |
| ១៣ | ខេត្តកែប | ផ្លូវលេខ ៣៣A, ភូមិអូរក្រសា, សង្កាត់អូរក្រសា,<br>ក្រុងកែប, ខេត្តកែប | ០៩៣ ៩៣៣ ៣៨៣ | N/A | N/A |
| ១៤ | ខេត្តកោះកុង | ផ្ទះលេខ២៦, ក្រុម០២, ភូមិ០៣, សង្កាត់ដងទង់,<br>ក្រុងខេមរភូមិន្ទ, ខេត្តកោះកុង | ០៩៧ ៩៧៣ ៩០០៦<br>០១២ ៦២៥ ៨៥៥ | ០៣៥ ៩៣៦ ៤៣៦ | kongkea.nssf.kk@gmail.com |
| ១៥ | ខេត្តបាត់ដំបង | ផ្ទះលេខK2 117, ផ្លូវ ១១៦ ភូមិរំចេក៤, សង្កាត់រតនៈ,<br>ក្រុងបាត់ដំបង, ខេត្តបាត់ដំបង | ០៩៧ ៩៩៧ ២៨២៩ | ០៥៣ ៩៥៣ ៣៣៦ | battambang@nssf.gov.kh |
| ១៦ | ខេត្តប៉ៃលិន | ភូមិវត្ត, សង្កាត់ប៉ៃលិន, ក្រុងប៉ៃលិន, ខេត្តប៉ៃលិន | ០៨៦ ៨៩៣ ៧៧៧ | ០៥៥ ៩៥៦ ៦៦៧ | somit.ream@nssf.gov.kh |
| ១៧ | ខេត្តពោធិ៍សាត់ | ផ្ទះលេខ០០៧, ភូមិរាំ, សង្កាត់ផ្ទះព្រៃ, ក្រុងពោធិ៍សាត់,<br>ខេត្តពោធិ៍សាត់ | ០៩២ ៧០៧ ៣៨៥ | ០៥២ ៩៥១ ១២៣ | nssf_ps@nssf.gov.kh |
| ១៨ | ខេត្តកំពង់ធំ | ភូមិទី០៧,សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន, ខេត្តកំពង់ធំ | ០៩២ ៧៤៧ ០៩៩ | ០៦២ ២១០ ៤៦៣ | ly_sokha2007@yahoo.com |
| ១៩ | ខេត្តស្ទឹងត្រែង | ភូមិថ្មលាត, សង្កាត់ស្រះឫស្សី, ក្រុងស្ទឹងត្រែង,<br>ខេត្តស្ទឹងត្រែង | ០១២ ៨០៥ ៨៥១ | | nganrachana@gmail.com |
| ២០ | ខេត្តរតនគិរី | ភូមិទេសអន្លង, សង្កាត់បឹងកន្សែង, ក្រុងបាលុង, ខេត្ត<br>រតនគិរី | ០១១ ៨៥១ ៧៧៧<br>០៩៧ ៩៦៦ ៧៦៦៦ | ០៧៥ ៩៧៤ ១៨៤ | sam_ath@nssf.gov.kh |
| ២១ | ខេត្តមណ្ឌលគិរី | ភូមិចំបក់, សង្កាត់ស្ពានមានជ័យ, ក្រុងសែនមនោរម្យ,<br>ខេត្តមណ្ឌលគិរី | ០១២ ២០៥ ៧៥៦<br>០៨៨ ៨២០ ៥៧៥៦ | N/A | kosol_vicheth@yahoo.com |
| ២២ | ខេត្តឧត្តរមានជ័យ | ភូមិឈូក, សង្កាត់សំរោង, ក្រុងសំរោង,<br>ខេត្តឧត្តមានជ័យ | ០៩៧ ៥២៣ ៤៦៦៦<br>០៨៥ ៣១១ ៣០០ | N/A | simmao2013@gmail.com |

| ល.រ | ខេត្ត | អាសយដ្ឋាន | លេខទូរស័ព្ទដៃ | លេខទូរស័ព្ទលើតុ | E-mail |
|---|---|---|---|---|---|
| ២៣ | ខេត្តព្រះវិហារ | ភូមិកណ្តាល, សង្កាត់កំពង់ប្រណាក, ក្រុងព្រះវិហារ, ខេត្តព្រះវិហារ | ០៩៧ ៣៦៦ ៦០៦០<br>០១២ ២៥៩ ២៥៨ | N/A | nssf_pvh@nssf.gov.kh<br>savuthnou22@gmail.com |
| ២៤ | សាខាខណ្ឌដង្កោ | ផ្ទះលេខA04, ផ្លូវ៣០ម៉ែត្រ, ភូមិស្រាំដោក, សង្កាត់ពងទឹក, ខណ្ឌដង្កោ, រាជធានីភ្នំពេញ | ០១២ ៦៩៥ ៥៥០<br>០៨៦ ២៧១ ៣៧១ | ០២៣ ៩៩៥ ៤៨៤ | lpl@nssf.gov.kh |
| ២៥ | សាខាខណ្ឌឫស្សីកែវ | ផ្ទះលេខ០៦, ផ្លូវលេខ៣៤២(ផ្លូវទៅព្រែកភ្នំពេញ) កែងផ្លូវ៥៩៨, ភូមិ៤, មណ្ឌល៦, សង្កាត់ច្រាំងចំរេះទី១, ខណ្ឌឫស្សីកែវ, រាជធានីភ្នំពេញ | ០៩២ ៤៨៦ ២៥៦<br>០៨៨ ៦៩១ ១៩១១ | ០២៣ ៦៦៣ ៣០៣០ | vannaknssf@nssf.gov.kh |
| ២៦ | សាខាខណ្ឌមានជ័យ | បុរីប៉េងហួត, ផ្ទះលេខ៤៣, ផ្លូវ P-១០C, សង្កាត់និរោធ, ខណ្ឌច្បារអំពៅ, រាជធានីភ្នំពេញ | ០៧៧ ៣៦៦ ៥៥៥ | ០២៣ ៩០១ ៥៣០ | Lay.sovan@nssf.gov.kh |
| ២៧ | សាខាខណ្ឌពោធិ៍សែនជ័យ | ផ្ទះលេខ៣១, ផ្លូវសម្តេចជាស៊ីម, សង្កាត់ព្រែកលាភ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ | ០១២ ៩៩១ ៥៥៨ | 023 901 529 | sovanrithsom@gmail.com |

នស/រកត/០២១៧/០៧៨

# ព្រះរាជក្រឹត្យ
## ស្តីពី
## ការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនិង ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ-កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ-កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះ មានគោលដៅផ្តល់ជូននូវតាវកាលិកសន្តិសុខសង្គម ផ្នែកហានិភ័យការងារចំពោះមន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពចំពោះមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

**មាត្រា៣ .-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ៖

១. មន្ត្រីសាធារណៈដូចខាងក្រោម៖

ក. មន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

ខ. មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

គ. មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ។

ឃ. មន្ត្រីនគរបាលជាតិ។

ង. មន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ។

២. អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន។

៣. មន្ត្រីសាធារណៈក្រៅពីចំណុច១ខាងលើនិងអ្នកនៅក្នុងបន្ទុកដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យដោយផ្អែកលើស្ថានភាពសង្គមនិងសេដ្ឋកិច្ចជាក់ស្តែង។

ចំពោះរបបសន្តិសុខសង្គមសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នឹងមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤** .-

វាក្យសព្ទបច្ចេកទេស ដែលប្រើនៅក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សំដៅដល់ការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ
- គ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយមន្ត្រីសាធារណៈដោយធ្វើការឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួន
- គ្រោះថ្នាក់ពេលធ្វើដំណើរ សំដៅដល់គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយមន្ត្រីសាធារណៈក្នុងពេលធ្វើដំណើរពីលំនៅឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការឬវិលមកវិញដោយគ្មានឈប់ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ក្រៅពីការងារដែលក្រសួង ស្ថាប័ន ឬអង្គភាពតម្រូវឱ្យទៅ
- ជំងឺវិជ្ជាជីវៈ សំដៅដល់ជំងឺនានាដែលកើតឡើងដោយមានមូលហេតុពីការងារឬពាក់ព័ន្ធនឹងការងារ ទោះជាជំងឺនោះកើតឡើងក្នុងកំលុងពេលបំពេញការងារឬក្នុងពេលណាមួយក្រោយបំពេញការងារក៏ដោយ
- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវផ្តល់ការគាំពារចំពោះគ្រោះថ្នាក់ ឬជំងឺ ដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ
- តារាលិកផ្នែកហានិភ័យការងារសំដៅដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ វិភាជន៍ឬធនលាភបាត់បង់សមត្ថភាពការងារសម្រាប់ផ្តល់ជូនមន្ត្រីសាធារណៈដែលរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ និងធនលាភឧត្តរជីវីសម្រាប់ផ្តល់ជូនសិទ្ធិវន្តនៃជនរងគ្រោះ ដែលរងគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ បណ្តាលឱ្យបាត់បង់ជីវិត
- តារាងលិកផ្នែកថែទាំសុខភាព សំដៅដល់សេវាបង្ការសុខភាពនិងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សម្រាប់ផ្តល់ជូនជនទាំងឡាយដូចមានចែងក្នុងមាត្រា៣ខាងលើ

- ភាគទាន សំដៅដល់ប្រាក់ដែលមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងរដ្ឋត្រូវបង់តាមច្បាប់ទុកជាមូលនិធិសម្រាប់ការផ្តល់តាវកាលិក
- អតីតមន្ត្រីរាជការ សំដៅដល់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ
- អតីតយុទ្ធជន សំដៅដល់និវត្តជន ជនពិការ និងជនបាត់បង់សមត្ថភាពការងារ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស.) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៦ .-**

សមាជិកក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ដែលមកពីផ្នែកសាធារណៈ ត្រូវមានសមត្ថកិច្ចក្នុងការប្រជុំពិភាក្សានិងអនុម័តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈនិងអតីតមន្ត្រីរាជការ អតីតយុទ្ធជនដោយមានការអញ្ជើញតំណាង បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល(ប.ជ.ស.) បេឡាជាតិអតីតយុទ្ធជន(ប.ជ.អ.) មូលនិធិជនពិការ(ម.ជ.ព.) និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្តល់យោបល់។

សេចក្តីសម្រេចដែលក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម បានប្រជុំពិភាក្សា និងអនុម័ត ត្រូវសុំការពិនិត្យនិងយល់ព្រមពីក្រសួងអាណាព្យាបាលបច្ចេកទេសនិងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ ទៅតាមសមត្ថកិច្ចរៀងៗខ្លួន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## ភាគទាន តាវកាលិក និងប្រាក់ត្រៀមបម្រុង
### ផ្នែកទី១
### របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ

**មាត្រា៧ .-**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ គឺជាបន្ទុករបស់រដ្ឋ ស្ថាប័ន ឬអង្គភាពគ្រប់គ្រងផ្ទាល់។

អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានក្នុងផ្នែកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

**មាត្រា៨ .-**

តាវកាលិកនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ មានដូចខាងក្រោម៖

- ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- ប្រាក់វិភាជសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០%
- ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%ឡើង
- វិភាជន៍បូជាសព ធនលាភឧត្តរជីវី សម្រាប់សហព័ទ្ធនិងកូន ព្រមទាំងជនចាស់ជរាពុំមានប្រាក់ចំណូលដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះដោយហានិភ័យការងារហេតុបាត់បង់ជីវិត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកសម្រាប់ផ្នែកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២
## របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
## សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន

**មាត្រា៩ .-**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជាបន្ទុករួមគ្នារវាងរដ្ឋ ស្ថាប័ន ឬអង្គភាពគ្រប់គ្រងផ្ទាល់ ជាមួយនឹងមន្ត្រីសាធារណៈ។

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ជាបន្ទុកផ្ទាល់របស់សាមីខ្លួន។ អត្រាភាគទានដែលជាបន្ទុករបស់អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន មិនត្រូវលើសផ្នែកនៃភាគទានដែលជាបន្ទុករបស់មន្ត្រីសាធារណៈ។

អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានក្នុងផ្នែកនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០ .-**

តាវកាលិកនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មានដូចខាងក្រោម៖

- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រដែលរួមមាន ការផ្តល់សេវាព្យាបាលដោយសម្រាកក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជំងឺក្រៅ សេវាសង្គ្រោះបន្ទាន់ សេវាព្យាបាលដោយស្តុំនិងដោយចលនា សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាលនិងសេវាស្តារនីតិសម្បទា
- សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ ចំពោះករណីសង្គ្រោះបន្ទាន់ និងសេវាបញ្ជូនសពសេវាបង្ការសុខភាព។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកនៃផ្នែកនេះត្រូវកំណត់ដោយអនុក្រឹត្យ។



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៣
## ប្រាក់ត្រៀមបម្រុង

**មាត្រា១១ .-**

ប្រាក់ត្រៀមបម្រុងនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាលទាំងពីរ។

## ជំពូកទី៤
## ការទទួលស្គាល់និងការត្រួតពិនិត្យគុណភាពសេវា របស់មូលដ្ឋានសុខាភិបាល

**មាត្រា១២ .-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម។

**មាត្រា១៣ .-**

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងវាយតម្លៃដោយគណៈកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម។

## ជំពូកទី៥
## កិច្ចសម្របសម្រួលផ្នែកគ្រប់គ្រងទិន្នន័យ

**មាត្រា១៤ .-**

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មកបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព។

## ជំពូកទី៦
## ការអនុវត្ត

**មាត្រា១៥ .-**

ដំណាក់កាលនិងកាលបរិច្ឆេទជាក់លាក់សម្រាប់ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៧

នស/រកត.០២១៧/០៤០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា**
**អ៊ិត សំហេង**

លេខៈ ៧៤ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៧/៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្ដល់តាមកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៧

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន លើកលែងតែអតីតយោធិនដែលមានឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី ដែលត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

**មាត្រា២.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សំដៅដល់ការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ
- គ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ចំពោះរូបកាយមន្ត្រីសាធារណៈ ដោយធ្វើការ ឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួន

- គ្រោះថ្នាក់ពេលធ្វើដំណើរ សំដៅដល់គ្រោះថ្នាក់ចំពោះរូបកាយមន្ត្រីសាធារណៈក្នុងពេលធ្វើដំណើរពីលំនៅឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការឬវិលមកវិញដោយគ្មានឈប់ ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ក្រៅពីការងារដែលក្រសួង ស្ថាប័ន ឬអង្គភាពតម្រូវឱ្យទៅ
- ជំងឺវិជ្ជាជីវៈ សំដៅដល់ជំងឺនានាដែលកើតឡើងដោយមានមូលហេតុពីការងារឬពាក់ព័ន្ធនឹងការងារ ទោះជាជំងឺនោះកើតឡើងក្នុងកំលុងពេលបំពេញការងារឬក្នុងពេលណាមួយក្រោយបំពេញការងារក៏ដោយ
- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្ដល់ការគាំពារចំពោះគ្រោះថ្នាក់ ឬជំងឺ ឬបញ្ហាសុខភាពដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ
- តាវកាលិកផ្នែកហានិភ័យការងារ សំដៅដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ វិភាជន៍ ឬធនលាភបាត់បង់សមត្ថភាពការងារសម្រាប់ផ្ដល់ជូនមន្ត្រីសាធារណៈដែលរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ និងធនលាភឧត្តរជីវី សម្រាប់ផ្ដល់ជូនសិទ្ធិវន្តនៃជនរងគ្រោះ ដែលរងគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ បណ្ដាលឱ្យបាត់បង់ជីវិត
- ក្មេងកំព្រា សំដៅដល់ក្មេងកំព្រាដែលគ្មានឪពុកម្ដាយនិងរស់នៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះដោយហានិភ័យការងារ
- តាវកាលិកផ្នែកថែទាំសុខភាព សំដៅដល់សេវាបង្ការសុខភាពនិងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- សេវាបង្ការសុខភាព សំដៅដល់សកម្មភាពនានាដូចជា ការស្រាវជ្រាវរកជំងឺឬការកំណត់ជាមុននូវសញ្ញាណហានិភ័យផ្នែកសុខភាព ការអប់រំសុខភាព ការផ្ដល់ប្រឹក្សា កម្មវិធីចាក់ថ្នាំបង្ការ ឬអន្តរាគមន៍នានា ដើម្បីបង្ការកុំឲ្យមានបញ្ហាផ្នែកសុខភាព
- បច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សំដៅដល់បច្ចេកទេសឬវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យ ការព្យាបាលនិងថែទាំត្រឹមត្រូវតាមក្បួនវេជ្ជសាស្ត្រ ដែលធ្វើឡើងដោយអ្នកមានវិជ្ជាជីវៈ ទទួលស្គាល់ដោយគណៈវិជ្ជាជីវៈសុខាភិបាល និងត្រូវបានអនុញ្ញាតច្បាប់ឲ្យប្រកបមុខរបរតាមវិជ្ជាជីវៈដោយក្រសួងសុខាភិបាល
- សល្យសាស្ត្រ សំដៅដល់ការវះកាត់តាមរបៀបវេជ្ជសាស្ត្រក្នុងបំណងព្យាបាល
- មូលដ្ឋានសុខាភិបាល សំដៅដល់អង្គភាពសុខាភិបាលសាធារណៈឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- សេវាពិគ្រោះជំងឺក្រៅ សំដៅដល់សេវាពិនិត្យនិងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ

៧/១៤

- សេវាសង្គ្រោះបន្ទាន់ សំដៅដល់អន្តរាគមន៍ទាំងឡាយដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក និងត្រូវធ្វើជាបន្ទាន់ក្នុងគោលបំណងសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវយវៈ ឬសរីរាង្គណាមួយរបស់ជនរងគ្រោះឬអ្នកជំងឺ
- ថ្លៃតាមសេវា សំដៅដល់ថ្លៃសេវាព្យាបាលនីមួយៗរបស់មូលដ្ឋានសុខាភិបាល
- វិភាជន៍ សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវផ្តល់ជូនជនរងគ្រោះតែម្តងគត់
- ធនលាភ សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវផ្តល់ជូនជនរងគ្រោះដោយហានិភ័យការងារជាកាលិក
- ធនលាភឧត្តរជីវី សំដៅដល់ប្រាក់ឧបត្ថម្ភដែលបានផ្តល់ឲ្យប្តី ប្រពន្ធ ឬកូននៅក្នុងបន្ទុក...។

## ជំពូកទី២
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាមកាលិកផ្នែកហានិភ័យការងារ
### ផ្នែកទី១
### គោលការណ៍រួម

**មាត្រា៣ .-**

មន្ត្រីសាធារណៈដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារនៅពេលទទួលរងហានិភ័យការងារ។

ជនរងគ្រោះដោយហានិភ័យការងារឬសិទ្ធិវន្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស.**) និងក្រសួង ស្ថាប័ន ឬអង្គភាពសាមី អំពីគ្រោះថ្នាក់ដែលបានកើតឡើងចំពោះខ្លួន លើកលែងតែករណីប្រធានសក្តិ ឬការមិនមានលទ្ធភាព ឬមានមូលហេតុសមស្រប។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពសាមី ត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយ មកបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស.**)ពីឧបទ្ទវហេតុនៃហានិភ័យការងារយ៉ាងយូរ៤៨(សែសិបប្រាំបី)ម៉ោងនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការស្នើសុំព័ត៌មានពីប.ស.ស.។ សេចក្តីសន្និដ្ឋាននៃហានិភ័យការងារ ត្រូវបានកំណត់ដោយអនុលោមតាមលទ្ធផលនៃការអង្កេតហានិភ័យការងារដែលធ្វើឡើងដោយ **ប.ស.ស.**។

### ផ្នែកទី២
### ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

**មាត្រា៤ .-**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ រួមមាន៖

- ការព្យាបាលនិងថែទាំមុខរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ ទោះដោយសម្រាកឬមិនសម្រាកនៅក្នុងមន្ទីរពេទ្យក្តី រហូតដល់ជាសះស្បើយ

- ការផ្តល់សេវាសង្គ្រោះបន្ទាន់
- ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាលនិងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល
- ការផ្តល់សេវាស្តារនីតិសម្បទា មានជាអាទិ៍ ការផ្គត់ផ្គង់ ការថែទាំ ឬការជួសជុលឧបករណ៍អវយវៈ ឬសរីរាង្គសិប្បនិម្មិត ឬការកែទម្រង់រាងកាយដែលតម្រូវដោយគ្រូពេទ្យផ្លូវការ ការសម្របសម្រួលមុខងារ ឬការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈឡើងវិញ
- ការផ្តល់សេវាដឹកសពឬបញ្ជូនជនរងគ្រោះពេលសង្គ្រោះបន្ទាន់។

## ផ្នែកទី៣
## ការផ្តល់វិភាជន៍និងធនលាភ
## សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

**មាត្រា៥.-**

ក- មន្ត្រីសាធារណៈដែលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យមានការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០%(ម្តៃភាគរយ) មានសិទ្ធិទទួលបានវិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ដែលត្រូវបើកផ្តល់ជូនតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

**វ.ប.ក. = ប.ថ. x ក.ប.ក. x ២០%ម.ត.ប. ដែល៖**

- **វ.ប.ក.** គឺជាវិភាជន៍បាត់បង់សមត្ថភាពការងារ
- **ប.ថ.** គឺជាប្រាក់បៀវត្សប្រចាំថ្ងៃរបស់ជនរងគ្រោះ ដែលស្មើនឹងបៀវត្សមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះចែកនឹង២២ថ្ងៃ
- **ក.ប.ក.** គឺជាកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍របស់ជនរងគ្រោះ
- **ម.ត.ប.** គឺជាមេគុណតម្លៃបច្ចុប្បន្នគិតតាមអាយុរបស់ជនរងគ្រោះ។

ខ- មន្ត្រីសាធារណៈ ដែលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%(ម្តៃភាគរយ)ឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលត្រូវគិតតាមរូបមន្តដូចខាងក្រោម៖

**ធ.ល. = ប.ខ. x ៤/៥ក.ប.ក.** ដែល៖

- **ធ.ល.** គឺជាធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍
- **ប.ខ.** គឺជាប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះ

ការផ្តល់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាពនិងសមត្ថភាពការងារឡើងវិញក្នុងរយៈពេល១២(ដប់ពីរ)ខែយ៉ាងយូរ។ សាមីជនដែលទទួល

បានធនលាភនេះ ត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពនិងសមត្ថភាពការងារ តាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

ក្នុងករណីដែលមានតាវកាលិកត្រួតគ្នារវាងធនលាភនិងប្រាក់សោធន សាមីជនមានសិទ្ធិទទួលបានតែតាវកាលិកណាមួយដែលមានចំនួនទឹកប្រាក់ខ្ពស់ជាងប៉ុណ្ណោះ។

កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

គណៈកម្មការវេជ្ជសាស្ត្រនៃ**ប.ស.ស.** ឬគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ដោយ**ប.ស.ស.** ត្រូវកំណត់កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ក្នុងករណីដែលកម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍មិនមានចែងនៅក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

មេគុណតម្លៃបច្ចុប្បន្ន ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ការកែប្រែមេគុណតម្លៃបច្ចុប្បន្ន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤
## ការផ្តល់វិភាជន៍បូជាសពនិងធនលាភឧត្តរជីវី

**មាត្រា៦ .-**

ក្នុងករណីដែលមានហានិភ័យការងាររហូតដល់បាត់បង់ជីវិត អ្នកដែលមានករណីយកិច្ចចាត់ចែងបូជាសពជនរងគ្រោះ ត្រូវទទួលបានវិភាជន៍បូជាសពចំនួន១០(ដប់)លានរៀល។ វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។

វិភាជន៍បូជាសពនេះ អាចកែសម្រួលឡើងវិញដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧ .-**

ក្នុងករណីដែលមានហានិភ័យការងាររហូតដល់បាត់បង់ជីវិត សិទ្ធិវន្តនៃជនរងគ្រោះមានសិទ្ធិទទួលបានធនលាភឧត្តរជីវី។

សិទ្ធិវន្តនៃជនរងគ្រោះ ដោយហានិភ័យការងាររហូតបាត់បង់ជីវិត រួមមាន៖

ក- ប្តីឬប្រពន្ធរបស់សាមីជនរងគ្រោះ ដែលមានសំបុត្រអាពាហ៍ពិពាហ៍មុនពេលមានហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារនៃប្តីឬប្រពន្ធ

ខ- កូនដែលមានអាយុត្រឹម១៨(ដប់ប្រាំបី)ឆ្នាំចុះ ដែលមិនទាន់មានគូស្រករនិងមានស្ថានភាពដូចខាងក្រោម៖

- ជាកូនបង្កើត

- ក្នុងករណីមានការលែងលះឬករណីមរណភាពនៃប្តីឬប្រពន្ធ កូននៃគូស្រករក្រោយ ដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍ទីមួយដែរ។
- កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់២១(ម្ភៃមួយ)ឆ្នាំចុះ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនដែលកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈឬឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ព្រមទាំងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ។

ចំពោះកូនពិការឬមានជំងឺរ៉ាំរ៉ៃ ដែលមិនមានលទ្ធភាពធ្វើការងារមានប្រាក់ឈ្នួល មិនមានការកំណត់អាយុទេ។

គ- ឪពុកម្តាយឬមនុស្សចាស់ដែលមានអាយុយ៉ាងតិច៥៥(ហាសិបប្រាំ)ឆ្នាំ មិនមានប្រកបមុខរបរមានប្រាក់ចំណូល និងត្រូវនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ។

**មាត្រា៨ .–**

ធនលាភឧត្តរជីវី ត្រូវបានផ្តល់ជូនប្រចាំខែតាមរូបមន្តដូចខាងក្រោម៖

ក- ចំពោះសិទ្ធិវន្ត ជារួមមានប្តីឬប្រពន្ធ កូន និងឪពុកម្តាយ ឬមនុស្សចាស់នៅក្នុងបន្ទុក៖

- ប្តីឬប្រពន្ធ = ៣/៥ x ៦៣%**ប.ខ.** ដែល**ប.ខ.**ជាបៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣%ប.ខ.
- ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក = ៧%ប.ខ.

ខ- ចំពោះសិទ្ធិវន្តជារួមមាន ប្តីឬប្រពន្ធ និងកូន៖

- ប្តីឬប្រពន្ធ = ៣/៥ x ៧០%ប.ខ.
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%ប.ខ.

គ- ចំពោះសិទ្ធិវន្ត ជារួមមានប្តីឬប្រពន្ធ និងឪពុកម្តាយ ឬមនុស្សចាស់៖

- ប្តីឬប្រពន្ធ=២៨%ប.ខ.
- ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក =២៨%ប.ខ.

ឃ- ចំពោះសិទ្ធិវន្តជាប្តីឬប្រពន្ធឬកូននៅក្នុងបន្ទុក ធនលាភសម្រាប់ប្តីឬប្រពន្ធឬធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ៥៦%ប.ខ.

ង- ចំពោះសិទ្ធិវន្តជាឪពុកម្តាយឬមនុស្សចាស់ ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក=៣៥%ប.ខ.

ច- ចំពោះសិទ្ធិវន្តជារួមមានកូននិងឪពុកម្តាយឬមនុស្សចាស់៖

- ធនលាភសរុបសម្រាប់កូន២៨%ប.ខ.
- ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក=២៨%ប.ខ.។

**មាត្រា៩ .-**

សិទ្ធិទទួលបានធនលាភឧត្តរជីវី ត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- នៅពេលដែលសាមីជនទទួលមរណភាព
- ប្តីឬប្រពន្ធដែលមានគូស្រករថ្មី ទោះបីជាមានឬគ្មានសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីមានគូស្រករថ្មី។

**មាត្រា១០ .-**

អាជ្ញាយុកាលនៃសិទ្ធិទាមទារវិភាជន៍បូជាសពមានរយៈពេល១(មួយ)ឆ្នាំ។

អាជ្ញាយុកាលនៃសិទ្ធិទាមទារវិភាជន៍បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០% និងធនលាភ មានរយៈពេល៥(ប្រាំ)ឆ្នាំ។

## ជំពូកទី៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាការពារលើផ្នែកថែទាំសុខភាព

### ផ្នែកទី១

### គោលការណ៍រួម

**មាត្រា១១ .-**

ដើម្បីទទួលបានសេវាថែទាំសុខភាព មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដូចមានចែងនៅក្នុងមាត្រា៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយដែលបានបង់ភាគទាន ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួនឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដល់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម។ ចំពោះមន្ត្រីសាធារណៈដែលត្រូវបញ្ចូលក្នុងក្របខណ្ឌថ្មី ក្រសួង ស្ថាប័ន ឬអង្គភាពសាមី ត្រូវបញ្ជូនឈ្មោះមន្ត្រីសាធារណៈនោះមក**ប.ស.ស.**។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពមានសមត្ថកិច្ច ត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបានធ្វើបច្ចុប្បន្នកម្មរួច មកបេឡាជាតិរបបសន្តិសុខសង្គម រៀងរាល់៦(ប្រាំមួយ)ខែ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារនិងថែទាំសុខភាព។

គ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស. ត្រូវផ្តល់កិច្ចសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការគ្រប់គ្រង និងផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រតាមពិធីសារឬសេចក្តីណែនាំប្រតិបត្តិគ្លីនិករបស់ក្រសួងសុខាភិបាល។

# ផ្នែកទី២
# ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

**មាត្រា១២ ._**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ រួមមាន ការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជំងឺក្រៅ សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល សេវាព្យាបាលដោយស្ពំឬការព្យាបាលដោយចលនា និងសេវាស្តារនីតិសម្បទា និងសេវាសង្គ្រោះបន្ទាន់។

**មាត្រា១៣ ._**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

ក- ការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ រួមមាន៖

- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល (តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល)។

ខ- ការផ្តល់សេវាពិគ្រោះជំងឺក្រៅ រួមមាន៖

- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

គ- ការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយពេលសម្រាល។

ឃ- ការផ្តល់សេវាព្យាបាលដោយស្ពំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទាដទៃទៀត។

ង- សេវាសង្គ្រោះបន្ទាន់ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាល ដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម សាមីជនរងគ្រោះឬអ្នកតំណាង ត្រូវជូនដំណឹងជាបន្ទាន់មកបេឡាជាតិរបបសន្តិសុខសង្គម។

**មាត្រា១៤ ._**

សេវាព្យាបាលនិងថែទាំ ដូចមានចែងក្នុងចំណុច ក ខ គ និងឃ នៃមាត្រា១៣ខាងលើនេះ ត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គមប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀត មិនត្រូវបានផ្តល់ជូនឡើយ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

## ផ្នែកទី៣

## ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព

**មាត្រា១៥ ._**

ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។

ការផ្តល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជាឬសេវាបញ្ជូនសព ត្រូវផ្តល់ជូនតាមតម្លៃរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

## ផ្នែកទី៤

## ការផ្តល់សេវាបង្ការសុខភាព

**មាត្រា១៦ ._**

ការផ្តល់សេវាបង្ការសុខភាពអាចត្រូវបានផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិបង្ការសុខភាពឬកម្មវិធីបង្ការសុខភាពដទៃផ្សេងទៀត។

សេវាបង្ការសុខភាពដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ត្រូវអនុវត្តដូចគ្នានឹងកម្មវិធីបង្ការសុខភាពផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ផ្នែកទី៥

## សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល

**មាត្រា១៧ ._**

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររួមមាន៖

- ការព្យាបាលដោយឥតបង់ថ្លៃ ដែលកំណត់នៅក្នុងគោលនយោបាយសុខាភិបាលជាតិ
- ការពិនិត្យសុខភាពទូទៅ
- ការថែទាំធ្មេញ (ការសំអាត ការប៉ះ និងការដាក់ធ្មេញ)
- សេវាប្តូរភេទ
- ការព្យាបាល ឬវះកាត់កែសម្ផស្ស ឬកែលម្អផ្នែកណាមួយនៃរាងកាយ

- សេវាបង្កកំណើតសិប្បនិម្មិត
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ
- ការព្យាបាលដោយខ្លួនឯង
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត
- ការព្យាបាលញៀនសុរា ឬការព្យាបាលផ្តាច់គ្រឿងញៀន
- ការវះកាត់ដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូងឬសរសៃបេះដូង
- ការលាងឈាម។

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ដូចមានចែងក្នុងកថាខណ្ឌខាងលើ នៃមាត្រានេះ ត្រូវបានផ្តល់ជូន ក្នុងករណីត្រូវសង្គ្រោះបន្ទាន់។

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ដូចមានចែងក្នុងកថាខណ្ឌខាងលើ នៃមាត្រានេះ អាចពិនិត្យកែសម្រួលឡើងវិញដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្របតាមស្ថានភាពជាក់ស្តែង។

## ផ្នែកទី៦
## ការកំណត់ជំងឺរ៉ាំរ៉ៃ

**មាត្រា១៨ .-**

ការផ្តល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់តែឱសថសារវន្តដែលកំណត់ដោយក្រសួងសុខាភិបាលតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុករបស់សាមីជន។

បញ្ជីជំងឺរ៉ាំរ៉ៃ ត្រូវអនុវត្តដូចគ្នានឹងបញ្ជីជំងឺរ៉ាំរ៉ៃនៃផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ជំពូកទី៤
## លក្ខខណ្ឌ បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវា និងការទាមទារតាវកាលិក
## ផ្នែកទី១
## លក្ខខណ្ឌ បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារ

**មាត្រា១៩ .-**

ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈត្រូវបានទូទាត់សងតាមយន្តការថ្លៃតាមសេវា។

ការព្យាបាលមន្ត្រីសាធារណៈដែលរងគ្រោះដោយហានិភ័យការងារ ត្រូវតែអនុវត្តដោយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស.**ប៉ុណ្ណោះ។

ក្នុងករណីដែលសេវានេះ ធ្វើនៅមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស.** សាមីជនរងគ្រោះដោយហានិភ័យការងារ អាចទាមទារការទូទាត់ថ្លៃព្យាបាលនិងថែទាំវេជ្ជសាស្ត្របាន។ ការទូទាត់សងថ្លៃព្យាបាលនេះត្រូវអនុលោមតាមការកំណត់របស់**ប.ស.ស.**។

ក្នុងករណីសង្គ្រោះបន្ទាន់ ជនរងគ្រោះអាចទទួលសេវាសង្គ្រោះនៅមូលដ្ឋានសុខាភិបាលណាក៏ដោយដែលជិតបំផុត។ **ប.ស.ស.** ត្រូវទូទាត់សងថ្លៃសង្គ្រោះបន្ទាន់តាមតម្លៃសមស្របជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល។

**មាត្រា២០ .-**

សិទ្ធិនៃការទាមទារថ្លៃតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវមានអាជ្ញាយុកាលត្រឹមរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។

## ផ្នែកទី២
## លក្ខខណ្ឌ បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

**មាត្រា២១ .-**

ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវធ្វើតាមយន្តការទូទាត់ថ្លៃសេវាដូចគ្នានឹងយន្តការទូទាត់ថ្លៃសេវាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារលើកលែងតែការព្យាបាលជំងឺមហារីកដោយសារធាតុគីមី និងឱសថព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ក្រៅពីឱសថក្នុងបញ្ជីឱសថសារវន្ត ដែលត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។

**មាត្រា២២ .-**

សិទ្ធិនៃការទាមទារថ្លៃតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវមានអាជ្ញាយុកាលត្រឹមរយៈពេល១២(ដប់ពីរ) ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។

## ផ្នែកទី៣
## បែបបទនិងនីតិវិធីនៃការទាមទារតាវកាលិក

**មាត្រា២៣ .-**

បែបបទនិងនីតិវិធីនៃការទាមទារតាវកាលិកផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៥
## ប្រាក់ត្រៀមបម្រុង
### ផ្នែកទី១
### ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកហានិភ័យការងារ

**មាត្រា២៤.-**

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកហានិភ័យការងារ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ប្រាក់ត្រៀមបម្រុងសម្រាប់តាវកាលិករយៈពេលវែង យ៉ាងតិចត្រូវស្មើនឹងការចំណាយ សម្រាប់ធនលាភក្នុងកំលុងពេល២(ពីរ)ឆ្នាំចុងក្រោយ។

ខ- ប្រាក់ត្រៀមបម្រុងសម្រាប់តាវកាលិករយៈពេលខ្លី យ៉ាងតិចត្រូវស្មើនឹងពាក់កណ្តាលនៃការចំណាយលើតាវកាលិកដទៃក្រៅពីធនលាភក្នុងកំលុងពេល២(ពីរ)ឆ្នាំចុងក្រោយ។

### ផ្នែកទី២
### ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

**មាត្រា២៥.-**

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកថែទាំសុខភាព យ៉ាងតិចត្រូវស្មើនឹងការចំណាយលើតាវកាលិកផ្នែកថែទាំសុខភាព ក្នុងកំលុងពេល១(មួយ)ឆ្នាំចុងក្រោយ។

## ជំពូកទី៦
## យន្តការគាំទ្រ សម្របសម្រួល និងសហការ

**មាត្រា២៦.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញប្រកាសដើម្បីកំណត់នូវយន្តការគាំទ្រ សម្របសម្រួល និងសហការរវាង **ប.ស.ស.** និងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិឬអង្គភាពមានសមត្ថកិច្ច ក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

ការផ្តល់តាវកាលិកផ្នែកហានិភ័យការងារនិងតាវកាលិកផ្នែកថែទាំសុខភាព ក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមដំណាក់កាលនិងកាលបរិច្ឆេទដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៧

**ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាមការលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

## កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

## ផ្នែកទី១

## បញ្ជីនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុង

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយ |
|---|---|---|
| ១ | បាត់បង់ប្រអប់ដៃទាំងពីរឬកាត់នៅផ្នែកខាងលើ | ១០០ |
| ២ | បាត់បង់ប្រអប់ដៃមួយនិងប្រអប់ជើងមួយ | ១០០ |
| ៣ | កាត់ជើងឬភ្លៅទាំងពីរឬកាត់ជើងឬភ្លៅម្ខាងនិងបាត់ប្រអប់ជើងម្ខាង | ១០០ |
| ៤ | បាត់ចក្ខុប្រសាទដែលមិនអាចបំពេញការងារដោយប្រើការមើលបាន | ១០០ |
| ៥ | ខូចទ្រង់ទ្រាយមុខធ្ងន់ធ្ងរ | ១០០ |
| ៦ | ថ្លង់ទាំងស្រុង | ១០០ |

## ផ្នែកទី២

## បញ្ជីនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែក

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយ |
|---|---|---|
| ក- ការកាត់អវៈយវៈខាងលើ (ដៃណាក៏ដោយ) | | |
| ១ | កាត់សន្លាក់ស្មា | ៩០ |
| ២ | កាត់ក្រោមស្មាដែលគល់នៅតិចជាង ៨" ពីចុងនៃ acromion | ៨០ |
| ៣ | កាត់ ៨" ពីចុងនៃ acromion ទៅតិចជាង ៩" ក្រោមចុងនៃ olecranon | ៧០ |
| ៤ | បាត់ប្រអប់ដៃឬមេដៃនិងម្រាម៤នៃប្រអប់ដៃមួយ ឬកាត់ ៤,៥" ខាងក្រោមចុងនៃ olecranon | ៦០ |
| ៥ | បាត់មេដៃមួយ | ៣០ |
| ៦ | បាត់មេដៃមួយនិងឆ្អឹង metacarpal | ៤០ |
| ៧ | បាត់ម្រាមបួននៃប្រអប់ដៃម្ខាង | ៥០ |
| ៨ | បាត់ម្រាមបីនៃប្រអប់ដៃម្ខាង | ៣០ |
| ៩ | បាត់ម្រាមពីរនៃប្រអប់ដៃម្ខាង | ២០ |
| ១០ | បាត់ថ្នាំងចុងក្រោយនៃមេដៃ | ២០ |
| ខ- ការកាត់អវៈយវៈខាងក្រោម | | |
| ១១ | កាត់ប្រអប់ជើងទាំងពីរបណ្តាលឲ្យដើរខ្វិច | ៩០ |
| ១២ | កាត់តាម feet proximal ទាំងពីរទៅ metatarso-phalangeal joint | ៨០ |
| ១៣ | បាត់ម្រាមជើងទាំងអស់នៃប្រអប់ជើងទាំងពីរតាម metatarso-phalangeal joint | ៤០ |
| ១៤ | បាត់ម្រាមជើងទាំងអស់នៃ feet proximal ទាំងពីរទៅ proximal inter-phalangeal joint | ៣០ |

| | | |
|---|---|---|
| ១៥ | បាត់ម្រាមជើងទាំងអស់នៃ feet distal ទាំងពីរទៅ proximal inter-phalangeal joint | ២០ |
| ១៦ | កាត់ត្រគាក | ៩០ |
| ១៧ | កាត់ក្រោមត្រគាកសល់គល់មិនលើស ៥" ដោយវាស់ពីចុងនៃ great trenchanter | ៨០ |
| ១៨ | កាត់ក្រោមត្រគាកសល់គល់មិនលើស ៥" ដោយវាស់ពីចុងនៃ great trenchanter ប៉ុន្តែមិនហួសពីពាក់កណ្ដាលភ្លៅ | ៧០ |
| ១៩ | កាត់ក្រោមពាក់កណ្ដាលភ្លៅទៅ ៣,៥" ក្រោមជង្គង់ | ៦០ |
| ២០ | កាត់ក្រោមជង្គង់ដោយនៅសល់គល់លើសពី ៣,៥" ប៉ុន្តែមិនហួសពី ៥" | ៥០ |
| ២១ | កាត់ក្រោមជង្គង់ដោយនៅសល់គល់លើសពី ៥" | ៤០ |
| ២២ | កាត់ប្រអប់ជើងមួយបណ្ដាលឲ្យដើរទប់ខាងចុង | ៣០ |
| ២៣ | កាត់ពី foot proximal មួយទៅ metatarso-phalangeal joint | ៣០ |
| ២៤ | បាត់ម្រាមជើងទាំងអស់នៃប្រអប់ជើងម្ខាងតាម metatarso-phalangeal joint | ២០ |
| **គ- ភ្នែក ត្រចៀក** | | |
| ២៥ | បាត់ភ្នែកម្ខាង ដោយមិនមាន Complications ហើយភ្នែកម្ខាងទៀតនៅធម្មតា | ៤០ |
| ២៦ | បាត់បង់គំហើញភ្នែកម្ខាងដោយមិនមាន Complications ឬដោយគ្មានខូចទ្រង់ទ្រាយ គ្រាប់មួយទៀតនៅធម្មតា | ៣០ |
| ២៧ | ត្រចៀកម្ខាងថ្លង់ទាំងស្រុង | ២០ |
| **ឃ- ម្រាមដៃឆ្វេងឬស្ដាំ** | | |
| ចង្អុលដៃ | | |
| ២៨ | ទាំងមូល | ១៤ |
| ២៩ | ពីរថ្នាំង | ១១ |
| ៣០ | មួយថ្នាំង | ៩ |
| ៣១ | កាត់ចុងម្រាមដោយម៉ាស៊ីន តែមិនបាត់ឆ្អឹង | ៥ |
| ម្រាមកណ្ដាល | | |
| ៣២ | ទាំងមូល | ១២ |
| ៣៣ | ពីរថ្នាំង | ៩ |
| ៣៤ | មួយថ្នាំង | ៧ |
| ៣៥ | កាត់ចុងម្រាមដោយម៉ាស៊ីន តែមិនបាត់ឆ្អឹង | ៤ |
| នាងដៃនិងកូនដៃ | | |
| ៣៦ | ទាំងមូល | ៧ |
| ៣៧ | ពីរថ្នាំង | ៦ |
| ៣៨ | មួយថ្នាំង | ៥ |
| ៣៩ | កាត់ចុងម្រាមដោយម៉ាស៊ីន តែមិនបាត់ឆ្អឹង | ២ |
| **ង-ម្រាមជើងឆ្វេងឬស្ដាំ** | | |
| មេជើង | | |
| ៤០ | Through metatarso-phalangeal joint | ១៤ |

| | | |
|---|---|---|
| ៤១ | Part, with some loss of bone | ៣ |
| ម្រាមជើងដទៃទៀត | | |
| ៤២ | Through metatarso-phalangeal joint | ៣ |
| ៤៣ | Part, with some loss of bone | ១ |
| ម្រាមពីរនៃប្រអប់ជើងណាមួយ ដោយមិនគិតមេជើង | | |
| ៤៤ | Through metatarso-phalangeal joint | ៥ |
| ៤៥ | Part, with some loss of bone | ២ |
| ម្រាមបីនៃប្រអប់ជើងណាមួយ ដោយមិនគិតមេជើង | | |
| ៤៦ | Through metatarso-phalangeal joint | ៦ |
| ៤៧ | Part, with some loss of bone | ៣ |
| ម្រាមបួននៃប្រអប់ជើងណាមួយ ដោយមិនគិតមេជើង | | |
| ៤៨ | Through metatarso-phalangeal joint | ៩ |
| ៤៩ | Part, with some loss of bone | ៣ |

បញ្ជីនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍អាចកែសម្រួលបានដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្គាល់ :

- ការបាត់បង់សមត្ថភាពប្រើប្រាស់ទាំងស្រុងនិងអចិន្ត្រៃយ៍នៃអវយវៈ ឬសរីរាង្គណាមួយ ដូចមានចែងក្នុងតារាងខាង លើត្រូវចាត់ទុកដូចជាការបង់អវយវៈ ឬសរីរាង្គនោះ
- សញ្ញា « " » ហៅថាអ៊ីញ (inch) ដែល 1inch ≃ ២,៥៤ cm

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០១៧
**ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាមកាលិកផ្នែកហានិភ័យការងារសម្រាប់**
**មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

## តារាងមេគុណតម្លៃបច្ចុប្បន្ន

| អាយុ | មេគុណ |
|---|---|
| ០ | ១៣ ៧៧៣ |
| ១ | ១៣ ៨២៣ |
| ២ | ១៣ ៧៣៧ |
| ៣ | ១៣ ៦៤៨ |
| ៤ | ១៣ ៥៥៩ |
| ៥ | ១៣ ៤៦៩ |
| ៦ | ១៣ ៣៧៩ |
| ៧ | ១៣ ២៨៨ |
| ៨ | ១៣ ១៩៦ |
| ៩ | ១៣ ១០២ |
| ១០ | ១៣ ០០៧ |
| ១១ | ១២ ៩០៩ |
| ១២ | ១២ ៨០៩ |
| ១៣ | ១២ ៧០៥ |
| ១៤ | ១២ ៥៩៨ |
| ១៥ | ១២ ៤៨៨ |
| ១៦ | ១២ ៣៧៥ |
| ១៧ | ១២ ២៥៩ |
| ១៨ | ១២ ១៤៨ |
| ១៩ | ១២ ០២៦ |
| ២០ | ១១ ៩០៥ |
| ២១ | ១១ ៧៨២ |
| ២២ | ១១ ៦៥៨ |
| ២៣ | ១១ ៥៣១ |
| ២៤ | ១១ ៤០២ |
| ២៥ | ១១ ២៧២ |

| | |
|---|---|
| ២៦ | ១១ ១៤០ |
| ២៧ | ១១ ០០៥ |
| ២៨ | ១០ ៨៦៩ |
| ២៩ | ១០ ៧៣០ |
| ៣០ | ១០ ៥៩០ |
| ៣១ | ១០ ៤៤៨ |
| ៣២ | ១០ ៣០៣ |
| ៣៣ | ១០ ១៥៦ |
| ៣៤ | ១០ ០០៧ |
| ៣៥ | ៩ ៨៥៧ |
| ៣៦ | ៩ ៧០៤ |
| ៣៧ | ៩ ៥៤៩ |
| ៣៨ | ៩ ៣៩២ |
| ៣៩ | ៩ ២៣២ |
| ៤០ | ៩ ០៧១ |
| ៤១ | ៨ ៩០៧ |
| ៤២ | ៨ ៧៤១ |
| ៤៣ | ៨ ៥៧៣ |
| ៤៤ | ៨ ៤០២ |
| ៤៥ | ៨ ២២៩ |
| ៤៦ | ៨ ០៥៣ |
| ៤៧ | ៧ ៨៧៥ |
| ៤៨ | ៧ ៦៩៤ |
| ៤៩ | ៧ ៥១២ |
| ៥០ | ៧ ៣២៩ |
| ៥១ | ៧ ១៤២ |
| ៥២ | ៦ ៩៥៣ |
| ៥៣ | ៦ ៧៦០ |
| ៥៤ | ៦ ៥៦៤ |
| ៥៥ | ៦ ៣៦៦ |
| ៥៦ | ៦ ១៦៧ |
| ៥៧ | ៥ ៩៦៧ |
| ៥៨ | ៥ ៧៦៧ |

| | |
|---|---|
| ៥៩ | ៥ ៥៦៨ |
| ៦០ | ៥ ៣៧១ |
| ៦១ | ៥ ១៧៦ |
| ៦២ | ៤ ៩៨៨ |
| ៦៣ | ៤ ៧៩៣ |
| ៦៤ | ៤ ៦០៥ |
| ៦៥ | ៤ ៤១៩ |
| ៦៦ | ៤ ២៣៤ |
| ៦៧ | ៤ ០៥១ |
| ៦៨ | ៣ ៨៦៩ |
| ៦៩ | ៣ ៦៨៩ |
| ៧០ | ៣ ៥១១ |
| ៧១ | ៣ ៣៣៥ |
| ៧២ | ៣ ១៦២ |
| ៧៣ | ២ ៩៩៥ |
| ៧៤ | ២ ៨៣៧ |
| ៧៥ | ២ ៦៨៧ |
| ៧៦ | ២ ៥៤១ |
| ៧៧ | ២ ៣៩៩ |
| ៧៨ | ២ ២៥៩ |
| ៧៩ | ២ ១២២ |
| ៨០ | ១ ៩៨៨ |
| ៨១ | ១ ៨៥៦ |
| ៨២ | ១ ៧២៨ |
| ៨៣ | ១ ៦០៥ |
| ៨៤ | ១ ៤៨៦ |
| ៨៥ | ១ ៣៧២ |
| ៨៦ | ១ ២៦៣ |
| ៨៧ | ១ ១៦០ |
| ៨៨ | ១ ០៦៣ |
| ៨៩ | ៩៧១ |
| ៩០ | ៨៨៥ |
| ៩១ | ៨០៤ |

| | |
|---|---|
| ៩២ | ៧២៧ |
| ៩៣ | ៦៥៥ |
| ៩៤ | ៥៨៧ |
| ៩៥ | ៥២២ |
| ៩៦ | ៤៥៩ |
| ៩៧ | ៣៩៣ |
| ៩៨ | ៣១៤ |
| ៩៩ | ២៤៣ |
| ១០០ | ១៨២ |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខៈ ៤០៤ ក.ប/ប្រ.ក.ប.ស.ស

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសុខាភិបាល

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមភាពចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងកំណត់ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនជូនកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ។

**ប្រការ ២.-**

ប្រកាសអន្តរក្រសួងនេះ មានគោលដៅកំណត់អំពីយន្តការគ្រប់គ្រង និងការផ្ដល់តាវកាលិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនជូនកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ។

**ប្រការ ៣.-**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធ និងកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ។

**ប្រការ ៤.-**

វាក្យស័ព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសអន្តរក្រសួងនេះ មាននិយមន័យដូចខាងក្រោម៖

- កម្មករនិយោជិតក្រៅប្រព័ន្ធ សំដៅដល់កម្មករនិយោជិតដែលចុះកិច្ចសន្យាធ្វើការងារមួយ ដែលមានរយៈពេលមួយ មិនលើសពី ៨ ម៉ោង ក្នុងមួយសប្តាហ៍ ធ្វើការងារមួយពេលៗ ធ្វើឈប់ៗ ឬធ្វើការងារមួយរដូវៗ ហើយដែលបានចុះបញ្ជីក្នុង ប.ស.ស
- តាវកាលិកថៃទាំសុខភាពផ្នែកមូលនិធិសមធម៌សុខាភិបាល សំដៅដល់សេវាព្យាបាល និងថៃទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល
- មូលនិធិសមធម៌សុខាភិបាលសំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថៃទាំសុខភាព ដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈដែលរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស
- កម្មករជាប់លាប់ សំដៅដល់ជនដែលធ្វើការទៀងទាត់ក្នុងមុខការអ្វីមួយ និងដែលមានលក្ខណៈ ជាអចិន្ត្រៃយ៍ ហើយដែលទទួលបានរបបសន្តិសុខសង្គមផ្នែកថៃទាំសុខភាពតាមប្រព័ន្ធបង់ភាគទាន ដែលជាកាតព្វកិច្ចរបស់និយោជក
- ការសម្រាលកូន សំដៅដល់ការឲ្យកំណើតទារកដែលមានអាយុចាប់ពី ២៦(ម្ភៃប្រាំមួយ) សប្តាហ៍ឡើង នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ
- ការិយការី សំដៅដល់អ្នកមៅការដែលទទួលការងារពីនិយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន ដែលជ្រើសរើសកម្មករហត្ថពលិកដោយខ្លួនឯងតាមត្រូវការដើម្បីប្រតិបត្តិការងារ ឬផ្តល់សេវាណាមួយដោយគិតថ្លៃសរុប។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី

**ប្រការ ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**) ត្រូវទទួលបន្ទុកគ្រប់គ្រង និងចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ និងបើកប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនសម្រាប់កម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ។

## ជំពូកទី ៣
## តាវកាលិកថៃទាំសុខភាព និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន
## ផ្នែកទី ១
## តាវកាលិកថៃទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល

**ប្រការ ៦.-**

តាវកាលិកថៃទាំសុខភាព នៃប្រកាសអន្តរក្រសួងនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៧.-**

កម្មករនិយោជិតក្រៅប្រព័ន្ធត្រូវប្រើប្រាស់សេវាតាមប្រព័ន្ធផ្តល់សេវាពីថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលថ្នាក់ទាបទៅមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់ជាង។ ក្នុងករណីសង្គ្រោះបន្ទាន់ ជនរងគ្រោះ ឬអ្នកជំងឺ អាចចូលទៅទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត។

## ផ្នែកទី ២
## ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនចំពោះកម្មករនិយោជិតជាស្ត្រី

**ប្រការ ៨.-**

កម្មករនិយោជិតជាស្ត្រីទាំងអស់ ទាំងក្នុងនិងក្រៅប្រព័ន្ធ ដែលសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ដូចខាងក្រោម៖

ក. សម្រាលកូនទោល (មួយ) ទទួលបាន ៤០០ ០០០(បួនសែន)រៀល។

ខ. សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ៨០០ ០០០(ប្រាំបីសែន)រៀល។

គ. សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ២០០ ០០០(មួយលានពីរសែន)រៀល។

ប្រាក់ឧបត្ថម្ភនេះ ត្រូវផ្តល់ជូនដោយផ្ទាល់ពី **ប.ស.ស** ក្រោយពេលសម្រាលកូនទោះបីទារករស់ ឬស្លាប់ក៏ដោយ ។

## ជំពូកទី ៤
## ការចុះបញ្ជី
## ផ្នែកទី ១
## ការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ

**ប្រការ ៩.-**

និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានទាំងអស់ ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិតរបស់ខ្លួនមកក្នុង **ប.ស.ស** ទោះជាកម្មករនិយោជិតនោះ ជាកម្មករនិយោជិតជាប់លាប់ ឬកម្មករនិយោជិតម្តងម្កាលក៏ដោយ។

**ប្រការ ១០.-**

កម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ឬអ្នកតំណាងស្របច្បាប់ត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមអំពីភាពមានគភ៌ក្នុងរយៈពេលយ៉ាងយូរបីខែមុនកាលបរិច្ឆេទនៃការសម្រាលកូន។ ក្នុងករណីខកខានមិនបានជូនដំណឹង តាមពេលកំណត់នេះ សាមីខ្លួនឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់ក្រោយពេលសម្រាលកូនយ៉ាងយូរបំផុត ១ខែ បើពុំនោះសោតនឹងបាត់បង់សិទ្ធិក្នុងការទទួលបានប្រាក់ឧបត្ថម្ភបន្ថែមនេះ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | រដ្ឋមន្ត្រី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
|---|---|---|
| បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | ម៉ម ប៊ុនហេង | អ៊ិត សំហេង |

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ១. បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

| ល.រ | រាជធានី-ខេត្ត | ឆ្នាំ២០១៧ | | |
|---|---|---|---|---|
| | | ស.ហ | កម្មករ | ស្រី |
| 1 | ភ្នំពេញ | 4,435 | 627,637 | 389,029 |
| 2 | ខេត្តកណ្តាល | 431 | 144,257 | 111,280 |
| 3 | ខេត្តកំពង់ស្ពឺ | 173 | 85,662 | 71,866 |
| 4 | ខេត្តបន្ទាយមានជ័យ | 316 | 17,848 | 10,313 |
| 5 | ខេត្តសៀមរាប | 727 | 29,161 | 13,885 |
| 6 | ខេត្តព្រះសីហនុ | 280 | 35,873 | 22,188 |
| 7 | ខេត្តស្វាយរៀង | 160 | 55,658 | 37,498 |
| 8 | ខេត្តកំពង់ឆ្នាំង | 91 | 38,028 | 32,640 |
| 9 | ខេត្តកំពង់ចាម | 163 | 30,483 | 24,695 |
| 10 | ខេត្តក្រចេះ | 146 | 6,977 | 2,608 |
| 11 | ខេត្តតាកែវ | 137 | 38,966 | 32,624 |
| 12 | ខេត្តព្រៃវែង | 47 | 4,916 | 4,002 |
| 13 | ខេត្តកំពត | 73 | 6,958 | 3,129 |
| 14 | ខេត្តកែប | 40 | 493 | 182 |
| 15 | ខេត្តកោះកុង | 44 | 10,467 | 7,141 |
| 16 | ខេត្តបាត់ដំបង | 410 | 8,487 | 3,835 |
| 17 | ខេត្តប៉ៃលិន | 63 | 2,990 | 1,707 |
| 18 | ខេត្តពោធិ៍សាត់ | 160 | 10,122 | 7,803 |
| 19 | ខេត្តកំពង់ធំ | 148 | 6,189 | 2,433 |
| 20 | ខេត្តស្ទឹងត្រែង | 79 | 1,112 | 418 |
| 21 | ខេត្តរតនៈគិរី | 109 | 3,723 | 1,296 |
| 22 | ខេត្តមណ្ឌលគិរី | 55 | 1,255 | 419 |
| 23 | ខេត្តឧត្តរមានជ័យ | 53 | 3,348 | 1,674 |
| 24 | ខេត្តព្រះវិហារ | 38 | 1,125 | 406 |
| 25 | ខេត្តត្បូងឃ្មុំ | 129 | 11,114 | 4,476 |
| សរុប | | 8,507 | 1,182,849 | 787,547 |

## ២. បច្ចុប្បន្នភាព សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែក ជើង ថ្នាក់កណ្ដាល /ថ្នាក់ខេត្ត

| ល.រ | រាជធានី/ខេត្ត | ចំនួនស.ហ | ចំនួនកម្មករនិយោជិត | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| 1 | ភ្នំពេញ | 626 | 341,023 | 279,441 |
| 2 | ខេត្តកណ្ដាល | 155 | 128,103 | 102,401 |
| 3 | ខេត្តកំពង់ស្ពឺ | 82 | 64,943 | 55,199 |
| 4 | ខេត្តបន្ទាយមានជ័យ | 5 | 4,198 | 2,892 |
| 5 | ខេត្តសៀមរាប | 1 | 19 | 15 |
| 6 | ខេត្តព្រះសីហនុ | 31 | 15,356 | 12,687 |
| 7 | ខេត្តស្វាយរៀង | 31 | 30,998 | 25,990 |
| 8 | ខេត្តកំពង់ឆ្នាំង | 18 | 30,820 | 26,936 |
| 9 | ខេត្តកំពង់ចាម | 10 | 24,042 | 21,810 |
| 10 | ខេត្តក្រចេះ | - | - | - |
| 11 | ខេត្តតាកែវ | 45 | 36,306 | 31,018 |
| 12 | ខេត្តព្រៃវែង | 3 | 3,921 | 3,640 |
| 13 | ខេត្តកំពត | 5 | 2,447 | 2,176 |
| 14 | ខេត្តកែប | - | - | - |
| 15 | ខេត្តកោះកុង | 3 | 5,759 | 4,446 |
| 16 | ខេត្តបាត់ដំបង | 1 | 104 | 71 |
| 17 | ខេត្តប៉ៃលិន | - | - | - |
| 18 | ខេត្តពោធិ៍សាត់ | 2 | 7,032 | 6,599 |
| 19 | ខេត្តកំពង់ធំ | 1 | 13 | 12 |
| 20 | ខេត្តស្ទឹងត្រែង | - | - | - |
| 21 | ខេត្តរតនៈគិរី | - | - | - |
| 22 | ខេត្តមណ្ឌលគិរី | - | - | - |
| 23 | ខេត្តឧត្ដរមានជ័យ | - | - | - |
| 24 | ខេត្តព្រះវិហារ | - | - | - |
| 25 | ខេត្តត្បូងឃ្មុំ | 2 | 1,470 | 1,439 |
| សរុប | | 1,021 | 696,554 | 576,772 |



















លេខទូរស័ព្ទបន្ទាន់

24ម៉ោង/7ថ្ងៃ

Call: 1286

**អាសយដ្ឋាន៖** អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(ស្ថិតនៅក្នុងបរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

**ទូរស័ព្ទលេខ៖** ០២៣ ៨៨២ ៤៣៤, ០២៣ ៨៨១ ០១៥
០២៣ ៨៨១ ០១៦, ០២៣ ៨៨០ ៤១៧

**គេហទំព័រ៖** www.nssf.gov.kh

**អ៊ីម៉ែល៖** info@nssf.gov.kh

**Facebook Page៖** www.facebook.com/nssfpage